

ខែ សីហា ឆ្នាំ ២០២១

# ការបញ្ចូលប្រធានបទស្តីពី អាហារូបត្ថម្ភ និងយេនឌ័រ នៅក្នុងការគ្រប់គ្រងសហគមន៍ស្រះជម្រកត្រី - ប្រព័ន្ធជលផលតាមវាលស្រែ៖ ឯកសារសម្រាប់អ្នកអនុវត្តន៍

ជាកកឹលីន ស្ស៊ី ឌីណា អ៊ាម សៅ សុខ ហាយ ឡុង វ៉ាន់រុធ ទ្រី វិចិត្រ ស៊ាន វឌ្ឍនៈ ស៊ុន ពេជ្រហុង អ៊ូ និង សារ៉ា ហ្វ្រីដ

## ការចុះសេចក្តីយោង

ពេលដកស្រង់ខ្លឹមសារនៃឯកសារនេះ គួរចុះសេចក្តីយោងថា៖ Shieh J, Eam D, Sok S, Long H, Try V, Sean V, Sun V, Ou P, and Freed S. 2021. Integrating nutrition and gender into Community Fish Refuge-Rice Field Fisheries system management: A practitioner’s guide. Phnom Penh, Cambodia: WorldFish Cambodia.

## អំពីអង្គការវើលហ្វីស (WorldFish)

វើលហ្វីស ជាអង្គការស្រាវជ្រាវអន្តរជាតិ មិនស្វែងរកផលចំណេញ ដែលប្រើប្រាស់សក្តានុពលនៃធនធានជលផល និងវារីវប្បកម្ម ដើម្បីកាត់បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រ។ នៅទូទាំងពិភពលោក ប្រជាពលរដ្ឋក្រីក្រជាងមួយពាន់លាននាក់ ទទួលបានប្រូតេអ៊ីនពីសាច់សត្វ ភាគច្រើនពីត្រី ហើយពលរដ្ឋ ៨០០លាននាក់ ពឹងផ្អែកលើធនធានជលផល និងវារីវប្បកម្ម សម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ អង្គការ WorldFish ជាសមាជិកនៃ CGIAR ដែលជាដៃគូស្រាវជ្រាវសកល ដើម្បីសន្តិសុខស្បៀងទៅអនាគត។

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះដៃគូរដ្ឋាភិបាលក្នុងគម្រោងបង្កើនធនធានជលផលតាមវាលស្រែ(RFFEP) និងគម្រោងធនធានជលផលតាមវាលស្រែនៃកម្មវិធីសន្តិសុខស្បៀងសម្រាប់អនាគតកម្ពុជា ជំហានទី២ ដែលរួមមាន ប្រធានរដ្ឋបាលជលផល រដ្ឋបាលជលផលថ្នាក់ជាតិ និងខណ្ឌរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋានក្នុងខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប និងកំពង់ធំ។ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណផងដែរចំពោះ អង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានសហការជាមួយអង្គការវើលហ្វីស ក្នុងការអនុវត្តគម្រោងទាំងពីរ ជាអាទិ៍៖ អង្គការអភិវឌ្ឍន៍នារីខ្មែរ (ANKO) អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) អង្គការអ្នកត្រួសត្រាយកម្ពុជា (TCO) និងក្រុមទ្រទ្រង់ភូមិ (VSG)។

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះបុគ្គលជាច្រើន ដែលបានរួមចំណែកក្នុងការរៀបចំឯកសារណែនាំនេះ ជាពិសេស លោក ម៉ម កុសល (WorldFish Cambodia) ដែលបានផ្តល់យោបល់ជំនាញប្រកបដោយការពិចារណា។ សូមអរគុណជាពិសេស ចំពោះអ្នកទាំងឡាយដែលបានចូលរួមក្នុងគម្រោងនេះ ដែលបានចំណាយពេលផ្តល់គំនិតដល់ពួកយើងអំពីបទពិសោធន៍របស់ខ្លួន។

លើសពីនេះ អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ សមាជិកនៃគណៈកម្មការសហគមន៍ស្រះជម្រកត្រីទាំង ១៤០ និងសមាជិកដទៃទៀតនៃសហគមន៍ ដែលបានជួយដល់ការកែលំអ និងការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ តាមរយៈការឧបត្ថម្ភពីការិយាល័យនានានៃខណ្ឌរដ្ឋបាលជលផល ដែលរួមចំណែកបង្កើនបរិមាណត្រី និងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមតំបន់ជុំវិញ។

## អាសយដ្ឋានទាក់ទង

អង្គការវើលហ្វីស-កម្ពុជា៖ ផ្ទះលេខ ១៨ ផ្លូវលេខ ៤១០ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
អ៊ីម៉េល៖ worldfish-cambodia@cgiar.org

### Creative Commons License

ខ្លឹមសារក្នុងឯកសារនេះ ស្ថិតក្រោមកិច្ចការពារដោយអាជ្ញាប័ណ្ណ Creative Commons Attribution-NonCommercial-NoDerivatives 4.0 International (CC BY-NC-ND 4.0) ដែលអនុញ្ញាតឱ្យប្រើប្រាស់ ចែកចាយ និងផលិតឡើងវិញ សម្រាប់តែក្នុងគោលដៅមិនមែនពាណិជ្ជកម្ម ក្នុងករណីបានផ្តល់សេចក្តីយោងសមស្របទៅឯកសារដើម ដោយគ្មានការកែប្រែ ផ្លាស់ប្តូរ ឬបន្ថែមខ្លឹមសារឡើយ ទោះតាមវិធីណាក៏ដោយ។

© 2019 WorldFish.

## ម្ចាស់រូបថត

លឹម សុភ័ណ្ឌ (រូបថតក្រប)

Fani Llaurado (រូបថត ១-៩)

## ការបដិសេធ

ការរៀបចំឯកសារនេះបានធ្វើឡើងក្រោមជំនួយគាំទ្រដ៏សប្បុរសពីប្រជាជនអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្នុងកិច្ចផ្តួចផ្តើមនៃកម្មវិធីសន្តិសុខស្បៀងសម្រាប់អនាគត (Feed the Future)។ ទស្សនៈរបស់អ្នកនិពន្ធដែលមានក្នុងឯកសារនេះ មិនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

# មាតិកា

ពាក្យបំព្រួញ ..... i
**១សេចក្តីផ្តើម** ..... 1
១១ ប្រព័ន្ធផលផលតាមវាលស្រែ និងស្រះជម្រកត្រី. ..... 1
១ ២.ហេតុអ្វីបញ្ចូលប្រធានបទស្តីពីអាហារូបត្ថម្ភ? ..... 1
១៣ ហេតុអ្វីបញ្ចូលប្រធានបទស្តីពី យេនឌ័រ. ? ..... 2
១៤ តើឯកសារណែនាំនេះរៀបចំឡើងសម្រាប់អ្នកណា និងមានគោលដៅអ្វីខ្លះ. ? ..... 2
**២ការអនុវត្តសកម្មភាពអាហារូបត្ថម្ភ និងយេនឌ័រ** . ..... 3
២១ ការបណ្តុះបណ្តាលអ្នកថែទាំកុមារអំពីអាហារូបត្ថម្ភ និង. WASH ..... 5
២២ ការបង្កើតចក្ខុវិស័យតាមគ្រួសារ. ..... 5
២៣ ពិព័រណ៍ភូមិ. ..... 7
២៤ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពរបស់គណៈកម្មការ. CFR ..... 7
**៣កត្តាអំណោយផលអន្តរវិស័យ និងឧបសគ្គ** ..... 8
៣១ កត្តាអំណោយផល. ..... 8
៣១ បង្កើតទំនាក់.១.ទំនងជាមួយសហគមន៍ និងបង្កលក្ខណៈឱ្យសហគមន៍មានភាពម្ចាស់ការ ..... 8
៣២ បង្កើតនិងរក្សាទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នរដ្ឋាភិបាល.១. ..... 9
៣៣ សមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់.១. ..... 10
៣២ ឧបសគ្គ ..... 11
៣១ វិសមភាពជាទូទៅនៃនិយាមយេនឌ័រ.២. ..... 11
៣២.២. ការយល់ថា អ្នកចូលរួមមានកម្រិតទាបនៃការចេះអក្សរ និងការធ្វើចំណាកស្រុកជាញឹកញាប់ ..... 12
**៤សកម្មភាពអំណោយផល និងឧបសគ្គ** . ..... 12
៤១ ការបណ្តុះបណ្តាលដល់អ្នកថែទាំកុមារ និងការបង្កើតចក្ខុវិស័យតាមគ្រួសារ. ..... 12
៤១ សកម្មភាពអំណោយផល.២. ..... 12
៤៣ យុទ្ធសាស្ត្របណ្តុះបណ្តាលដែលមានប្រសិទ្ធភាព.១. ..... 13
៤៤ ឧបសគ្គ និងអនុសាសន៍.១. ..... 14
៤២ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនៃគណៈកម្មការ. CFR ..... 14
៤១ កត្តាអំណោយផល.២. ..... 14
**សេចក្តីសន្និដ្ឋាន** ..... 17
**ឯកសារយោង** ..... 18
ឧបសម្ព័ន្ធ ១៖ សញ្ញាណ និងសារសំខាន់ៗអំពីអាហារូបត្ថម្ភ និង WASH សម្រាប់បណ្តុះបណ្តាលអ្នកថែទាំកុមារ ..... 19
ឧបសម្ព័ន្ធ ២៖ ការណែនាំសម្រាប់សម្របសម្រួលវគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ ..... 21
ឧបសម្ព័ន្ធ ៣៖ ការណែនាំសម្រាប់រៀបចំពិព័រណ៍ភូមិ ..... 23
ឧបសម្ព័ន្ធ ៤៖ ផ្ទាំងរូបភាពអំពីរបៀបធ្វើម្ជូរត្រី ..... 26

# ពាក្យបំព្រួញ

| | | |
|---|---|---|
| CFR | Community Fish Refuge | សហគមន៍ស្រះជម្រកត្រី |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FiAC | Fisheries Administration Cantonment | ខណ្ឌរដ្ឋបាលជលផល |
| RFF | Rice field fisheries | ជលផលតាមវាលស្រែ |
| SBCC | Social behavior change communication | ការប្រាស្រ័យទាក់ទងដើម្បីកែប្រែឥរិយាបថ |
| VHSG | Village health support group | ក្រុមទ្រទ្រង់សុខភាពភូមិ |
| WASH | Water, sanitation, and hygiene | ទឹក អនាម័យ និងការរស់នៅស្អាត |

# ១. សេចក្ដីផ្ដើម

## ១.១ ប្រព័ន្ធជលផលតាមវាលស្រែ និងស្រះជម្រកត្រី

ការនេសាទតាមវាលស្រែ ដែលធ្វើឡើងនៅក្នុង និងទីជុំវិញវាលស្រែ ជាពិសេសក្នុងរដូវទឹកជំនន់ គឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណូល ចំណីអាហារ និងអាហារូបត្ថម្ភនៅកម្ពុជា។ គ្រួសារជាច្រើននៅជនបទ បានធ្វើនេសាទតាមវាលស្រែ សម្រាប់ការបរិភោគក្នុងគ្រួសារ និង/ឬសម្រាប់បំពេញបន្ថែមលើរបរចិញ្ចឹមជីវិតរបស់ខ្លួន។ ការនេសាទតាមវាលស្រែក្នុងតំបន់បឹងទន្លេសាប ផ្ដល់ឱ្យគ្រួសារនានានូវផលនេសាទចំនួន ៦២% នៃបរិមាណផលនេសាទសរុបដែលគ្រួសារទាំងនោះបរិភោគ ហើយគ្រួសារក្នុងចំនួនរហូតដល់ ៦៥% បានលក់ផលនេសាទទាំងនោះជាប្រចាំ ឬ ម្ដងម្កាល (Freed et al. 2020)។

ការបង្កើត និងគ្រប់គ្រងសហគមន៍ស្រះជម្រកត្រី (CFR) គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពដើម្បីបង្កើនផលិតភាព និងជីវចម្រុះត្រីក្នុងប្រព័ន្ធជលផលដ៏សំខាន់នេះ។ CFR គឺជាទីជម្រកដែលមានទឹកគ្រប់រដូវនៅតាមតំបន់វាលស្រែ។ នៅពេលមានការគ្រប់គ្រងដោយនិរន្តរភាព តាមរយៈការធ្វើឱ្យប្រសើរឡើងនូវជម្រក និងកិច្ចការពារពីការនេសាទ ទីជម្រកទាំងនេះអាចបង្កើនបរិមាណត្រីនៅតាមតំបន់វាលស្រែ ដូច្នេះវាជួយដល់ការបង្កើនលទ្ធភាពសម្រាប់គ្រួសារនានានៅតាមមូលដ្ឋាន ក្នុងការទទួលបានត្រីសម្រាប់បរិភោគ។

ដោយទទួលស្គាល់ពីគុណតម្លៃនៃ CFR ទាំងនេះ តាំងពីឆ្នាំ ២០០៥មក រាជរដ្ឋាភិបាលកម្ពុជាបានជំរុញឱ្យមានការបង្កើត និងការគ្រប់គ្រងស្រះជម្រកត្រី (Joffre et al., 2012)។ ចាប់ពីឆ្នាំ ២០១២មក ដោយមានការគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) អង្គការ WorldFish បានធ្វើការជាមួយរដ្ឋបាលជលផល(FiA) ដើម្បីសាកល្បងនិងពង្រីកការអនុវត្តល្អលើការងារគ្រប់គ្រងនៅតាមទីតាំងនានាដែលមានស្រះជម្រកត្រីសហគមន៍ដែលបានកំណត់ដោយ FiA។

## ១.២ ហេតុអ្វីបញ្ចូលប្រធានបទស្ដីពីអាហារូបត្ថម្ភ?

អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅតែជាបញ្ហាប្រឈមដ៏សំខាន់ក្នុងប្រទេសកម្ពុជា ដែលនាំឱ្យមានផលវិបាកអវិជ្ជមាននានាចំពោះសុខភាព ផលិតភាពសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ បច្ចុប្បន្នកម្ពុជា ត្រូវលើកកំពស់អាហារូបត្ថម្ភសម្រាប់មាតា និងទារក (Development Initiatives Poverty Research, 2020)។ មានកត្តាជាច្រើន ដែលរួមចំណែកក្នុងបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់កុមារនៅកម្ពុជា ដែលរួមទាំងបញ្ហាប្រឈមលើរបៀបនៃការផ្ដល់ចំណីអាហារ អាហារូបត្ថម្ភ និងសុខភាពមាតា ព្រមទាំង ជំងឺរាក និងជំងឺដទៃទៀតដែលងាយឆ្លង នៅពេលខ្វះទឹកស្អាត អនាម័យ និងការរស់នៅស្អាត (WASH)។

នៅកម្ពុជា ត្រីដែលសម្បូរដោយសារជាតុចិញ្ចឹម ដែលអាចនេសាទបានតាមវាលស្រែ មានសក្ដានុពលក្នុងការលើកកំពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សម្រាប់គ្រួសារនៅជនបទ ដែលរួមទាំង ម្ដាយនិងកូន។ នៅឆ្នាំ ២០១៦ អ្នកស្រាវជ្រាវនិងអ្នកអនុវត្ត បានកែសម្រួលវិធីសាស្ត្រក្នុងការគ្រប់គ្រងCFR ដោយសន្មតថាការអនុវត្តអន្តរាគមន៍ដែលផ្ដោតលើអាហារូបត្ថម្ភនិងយេនឌ័រ ទន្ទឹមនឹងសកម្មភាពគ្រប់គ្រងផ្សេងទៀត អាចជួយសម្រេចបាននូវសក្ដានុពលនៃជលផលវាលស្រែ ដើម្បីលើកកំពស់អាហារូបត្ថម្ភ និងសន្តិសុខស្បៀងក្នុងមូលដ្ឋាន។

## ១.៣ ហេតុអ្វីបញ្ចូលប្រធានបទស្តីពី យេនឌ័រ ?

ស្ត្រីរួមចំណែកយ៉ាងសំខាន់ក្នុងការនេសាទខ្នាតតូច ទោះបីផលដែលបានពីការនេសាទខ្នាតតូច ច្រើនត្រូវគេមើលរំលង និងពុំមានការឱ្យតម្លៃបានសមស្របក៏ដោយ។ បុរស នៅតែជាអ្នកដែលមានឥទ្ធិពលធំជេងក្នុងការគ្រប់គ្រងជលផលជារួម។ នៅក្នុងការគ្រប់គ្រងជលផលតាមវាលស្រែនៅកម្ពុជា ភាគច្រើនស្ត្រីបានចូលរួមដោយប្រយោល តាមរយៈក្រុមសន្សំប្រាក់និងក្រុមឥណទាន ក៏ដូចជាក្រុមជួយខ្លួនឯងផងដែរ (The WorldFish Center, 2010)។ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់ពីការរួមចំណែក និងផលប្រយោជន៍របស់ស្ត្រីនៅក្នុងការគ្រប់គ្រងជលផលតាមវាលស្រែ គោលការណ៍អនុវត្តល្អក្នុងការគ្រប់គ្រង CFR ចែងថា សហគមន៍ត្រូវជ្រើសយក និងបណ្តុះបណ្តាលស្ត្រី ដើម្បីឱ្យបំពេញតួនាទីដឹកនាំក្នុងគណៈកម្មការគ្រប់គ្រង CFR។ ការអនុវត្តល្អបែបនេះ អាចបង្កើនការជឿជាក់ក្នុងសហគមន៍ និងការគាំទ្រដល់គណៈកម្មការ ហើយជាញឹកញាប់ ក៏ជួយសម្រេចគោលដៅគ្រប់គ្រងផងដែរ ដែលមិនត្រឹមតែជាការគ្រប់គ្រងទីជម្រកនិងវិធានការល្បាតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ជាគោលបំណងនានានៃការគាំទ្រដល់អាហារូបត្ថម្ភ និងសុខុមាលភាពគ្រួសារក្នុងមូលដ្ឋានផងដែរ។

## ១.៤ តើឯកសារណែនាំនេះរៀបចំឡើងសម្រាប់អ្នកណា និងមានគោលដៅអ្វីខ្លះ ?

ក្រុមមនុស្សដែលជាគោលដៅនៃឯកសារណែនាំនេះ គឺអ្នកអនុវត្តក្នុងវិស័យជលផលតាមវាលស្រែនៅកម្ពុជា ឬនៅប្រទេសដទៃ។ ឯកសារណែនាំនេះ មានបំណងជួយលុបបំបាត់គម្លាត រវាងផលនេសាទនៅតាមវាលស្រែ និងអត្ថប្រយោជន៍សម្រាប់សហគមន៍ទាំងមូល ជាពិសេស សុខភាពមាតានិងទារក ព្រមទាំង អាហារូបត្ថម្ភ និងភាពជាអ្នកដឹកនាំរួមគ្នា រវាងបុរសនិងស្ត្រី។ ឯកសារណែនាំនេះចែងអំពី៖

- ជំហាននានា និងដំណើរការនៃការធ្វើសមាហរណកម្មសកម្មភាពអាហារូបត្ថម្ភ និងយេនឌ័រ ទៅក្នុងការគ្រប់គ្រងជលផលតាមវាលស្រែ និងសហគមន៍ស្រះជម្រកត្រី និង
- ឧបសគ្គក្នុងការអនុវត្ត និងកត្តាអំណោយផលដល់សកម្មភាពទាំងនេះ។



*រូបថតទី ១៖ ម្តាយកំពុងបញ្ចុកបបរដល់កូន ដែលចំអិនលាយជាមួយត្រីដែលជាប្រភេទរកបានក្នុងមូលដ្ឋាន។*

## ២. ការអនុវត្តសកម្មភាពអាហារូបត្ថម្ភ និងយេនឌ័រ

សកម្មភាពអាហារូបត្ថម្ភនិងយេនឌ័រដូចខាងក្រោមនេះ ត្រូវបានធ្វើឡើងរួមជាមួយសកម្មភាពដើម្បីលើកកម្ពស់ការអនុវត្តល្អ សម្រាប់ការគ្រប់គ្រងជលផលតាមវាលស្រែនិងការគ្រប់គ្រងស្រះជម្រកត្រីសហគមន៍៖

- ការបណ្តុះបណ្តាលអំពីអាហារូបត្ថម្ភ និងWASH ដល់អ្នកថែទាំកុមារ
- ការបង្កើតចក្ខុវិស័យតាមគ្រួសារ និង
- ការបញ្ចូលស្ត្រីទៅក្នុងគណៈកម្មការ CFR។

សកម្មភាពទាំងនេះត្រូវបានធ្វើឡើងស្របគ្នា ដែលសកម្មភាពនីមួយៗជាការបំពេញបន្ថែម និងដែលរួមចំណែកជួយគ្នាទៅវិញទៅមក ដើម្បីផ្តល់នូវឥទ្ធិពល តាមរយៈទ្រឹស្តីនៃការផ្លាស់ប្តូរ (រូបទី ១)។ គេរំពឹងថា សកម្មភាពគ្រប់គ្រងជលផលតាមវាលស្រែនិងស្រះជម្រកត្រីសហគមន៍ នឹងជួយបង្កើនវត្តមានត្រី វារីសត្វដទៃទៀត និងរុក្ខជាតិទឹក និងការទទួលបានត្រី វារីសត្វដទៃទៀត និងរុក្ខជាតិទឹកទាំងនោះ សម្រាប់ការបរិភោគផងដែរ។ ចំណែកសកម្មភាពប្រាស្រ័យទាក់ទងដើម្បីកែប្រែឥរិយាបថសង្គម ដែលផ្តោតលើការលើកកំពស់អាហារូបត្ថម្ភ ក៏ត្រូវគេរំពឹងថា នឹងធ្វើឱ្យប្រសើរឡើងនូវការបរិភោគត្រី និងអត្ថប្រយោជន៍ខាងផ្នែកអាហារូបត្ថម្ភពីផលនេសាទផងដែរ សម្រាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសសម្រាប់កុមារអាយុក្រោម ៥ឆ្នាំ តាមរយៈការបង្កើនចំណេះដឹង ការកែប្រែឥរិយាបថ និងការអនុវត្តរបស់អ្នកថែទាំក្មេង និងគ្រួសារ ជុំវិញការលើកកំពស់អាហារូបត្ថម្ភ និងការយកចិត្តទុកដាក់លើ WASH។ ទន្ទឹមនឹងនេះ គេក៏រំពឹងថា សកម្មភាពបង្កើនការយល់ដឹងអំពីសមភាពយេនឌ័រ នឹងរួមចំណែកបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងជលផលតាមវាលស្រែ និងសហគមន៍ស្រះជម្រកត្រី ព្រមទាំង លទ្ធផលប្រសើរជាងមុនលើផ្នែកលើកកំពស់អាហារូបត្ថម្ភ និង WASH ផងដែរ។



*រូបថតទី ២៖ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយរូប ផ្តល់ការបណ្តុះបណ្តាលអំពីរបៀបលាងដៃ*

រូបភាពទី ១៖ ទ្រឹស្តីនៃការផ្លាស់ប្តូរ ដើម្បីសកម្មភាពអាហារូបត្ថម្ភនិងយេនឌ័រនៅក្នុងវិស័យជលផលតាមវាលស្រែ



## ២.១ ការបណ្តុះបណ្តាលអ្នកថែទាំកុមារអំពីអាហារូបត្ថម្ភ និង WASH

សកម្មភាពនេះផ្តល់ការបណ្តុះបណ្តាល ការគាំទ្រ និងការកែប្រែឥរិយាបថ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់អាហារបន្ថែម អាហារូបត្ថម្ភ អនាម័យ និងការរស់នៅស្អាត ដោយផ្តោតលើស្ត្រីមានផ្ទៃពោះ និងបំបៅដោះកូន ព្រមទាំងកុមារតូចៗផងដែរ។ វគ្គបណ្តុះបណ្តាល និងការគាំទ្រនេះ ត្រូវបានធ្វើឡើងជាពិសេស ជាមួយបណ្តាអ្នកថែទាំកុមារតូចៗ និងក្រុមអ្នកថែទាំកុមារតូចៗ (ចាប់ពីកើតដល់អាយុ ៥ឆ្នាំ)។ នៅក្នុងវគ្គបណ្តុះបណ្តាលនានា អ្នកសម្របសម្រួលផ្តល់ព័ត៌មាន និងអនុវត្តបង្ហាញ អំពីការធ្វើឱ្យប្រសើរឡើងនូវការផ្តល់អាហារបន្ថែម និងការអនុវត្តលើផ្នែកអនាម័យ។ សម្រាប់ការអនុវត្តបង្ហាញ ក្រុមអ្នកថែទាំកុមារអាចប្រមូលផ្តុំគ្នា ដើម្បីចូលរួមរៀបចំអាហារដែលមានជីវជាតិ ដែលមានគ្រឿងផ្សំក្នុងមូលដ្ឋាន ដូចជា ត្រីល្អិតៗដែលសំបូរសារជាតុចិញ្ចឹម និងបន្លែដែលមានក្នុងមូលដ្ឋាន ឬដើម្បីសង្កេតមើលវិធីកែលម្អភាពស្អាត និងអនាម័យផ្ទះសំបែង។ ដើម្បីសម្រួលដល់ពេលវេលាដែលមានក្នុងកម្រិតកំណត់របស់អ្នកថែទាំកុមារ វគ្គ បណ្តុះបណ្តាលនិងការអនុវត្តបង្ហាញ មិនគួរធ្វើឡើងច្រើនជាងពីរម៉ោងឡើយ និងគួរអនុវត្ត ឬមួយនៅពេលព្រឹក ឬពេលរសៀល អាស្រ័យតាមពេលវេលាដែលពួកគាត់មាន។ បញ្ជីលម្អិតនៃប្រធានបទសម្រាប់វគ្គបណ្តុះបណ្តាលក៏ដូចជាគំរូឧបករណ៍ និងសកម្មភាពបណ្តុះបណ្តាល មានបង្ហាញក្នុងឧបសម្ព័ន្ធ ១ ។



*រូបថតទី ៣៖ ឪពុកលាងដៃកូនរបស់គាត់នៅកន្លែងលាងដៃក្នុងគ្រួសាររបស់ពួកគាត់។*

## ២.២ ការបង្កើតចក្ខុវិស័យតាមគ្រួសារ

វគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ ជំរុញឱ្យមានការពិភាក្សាអំពីការធ្វើឱ្យប្រសើរឡើងនូវអនាម័យគ្រួសារជាពិសេស ក្នុងការរៀបចំម្ហូបអាហារ និងទីកន្លែងអនាម័យ ព្រមទាំងលើកទឹកចិត្តឱ្យមានសមភាពជុំវិញតួនាទីបុរសនិងស្ត្រីក្នុងគ្រួសារ។ ខណៈដែលគ្រួសារនីមួយៗរៀបចំកំណត់គោលបំណងរបស់ខ្លួន គោលដៅរួមនៃសកម្មភាពនេះគឺ ជួយសម្រួលឱ្យសមាជិកគ្រួសារចូលរួមក្នុងការកែលំអបរិយាកាសក្នុងផ្ទះសំបែង ទន្ទឹមនឹងធ្វើឱ្យប្រសើរឡើងនូវការចែករំលែកការងារក្នុងគ្រួសារប្រកបដោយសមធម៌ និងជួយសម្រួលដល់ស្ត្រីដែលចំណាយពេលច្រើននៅផ្ទះ ដើម្បីអាចធ្វើសកម្មភាពក្រៅផ្ទះផងដែរ (ជាញឹកញាប់គឺជាសកម្មភាពបង្កើតប្រាក់ចំណូល ដូចជា ការថែច្បារដំណាំ និងលក់បន្លែ និងករណីខ្លះ ក៏អាចជាការចូលរួមក្នុងការងារដឹកនាំនៅមូលដ្ឋានផងដែរ ដូចជា ក្នុងគណៈកម្មការ CFR)។ វគ្គពាក់ព័ន្ធ

នឹងការបង្កើតផែនទីចក្ខុវិស័យមួយអំពីបរិយាកាសគ្រួសារ និងតួនាទីបុរស និងស្ត្រីនៅពេលបច្ចុប្បន្ន និងផែនទីចក្ខុវិស័យទីពីរ ស្តីពីគោលដៅគ្រួសារនាពេលអនាគត និងតួនាទីដែលព្រមព្រៀងគ្នា ដែលត្រូវសម្រេចឱ្យបាន។ ការបណ្តុះបណ្តាលអំពីអាហារូបត្ថម្ភ និងWASH ត្រូវបានដាក់បញ្ចូលទៅក្នុងគោលដៅនិងផែនការសកម្មភាពសម្រាប់គ្រួសារ។ ឧបសម្ព័ន្ធ ២ បង្ហាញពីជំហាននានា សម្រាប់សកម្មភាពលំអិតនៃការបង្កើតចក្ខុវិស័យតាមគ្រួសារ។

- ជំហានទី ១៖ ផ្តល់ការណែនាំ និងលើកសំណួរដើម្បីសុំការបំភ្លឺអំពីទស្សនៈ និងការអនុវត្តបច្ចុប្បន្នរបស់ពួកគាត់ជុំវិញការបែងចែកនូវការទទួលខុសត្រូវ រវាងបុរសនិងស្ត្រី។
- ជំហានទី ២៖ សម្របសម្រួលឱ្យមានការពិភាក្សាអំពីភាពខុសគ្នា និងអតុល្យភាពយេនឌ័រ នៃតួនាទីក្នុងគ្រួសារ សហគមន៍និងសង្គម ដោយប្រើឧបករណ៍មួយថ្ងៃ២៤ម៉ោង ដើម្បីកត់ត្រាសកម្មភាពប្រចាំថ្ងៃរបស់បុរសនិងស្ត្រី។
- ជំហានទី ៣៖ ទាំងបុរសនិងស្ត្រីក្នុងគ្រួសារធ្វើវាយតម្លៃលទ្ធភាពទទួលបាននាពេលបច្ចុប្បន្ន និងគុណភាពអាហារអាហារូបត្ថម្ភ និងWASH (ឧទាហរណ៍អាហារដែលមានជីវជាតិ អាហារចម្រុះ បង្គន់ កន្លែងបោកគក់ ធុងសំរាម។ ល។)។ ពិភាក្សាអំពីការកែលំអនានា ដែលចាំបាច់ដើម្បីធ្វើឱ្យបរិយាកាសគ្រួសាររបស់ពួកគេកាន់តែប្រសើរ។
- ជំហានទី ៤៖ ជួយដល់បុរសនិងស្ត្រី ក្នុងការកំណត់គោលដៅ និងការប៉ងប្រាថ្នាសម្រាប់គ្រួសាររបស់ពួកគាត់ទៅអនាគត ដោយប្រើលទ្ធផលពីការវាយតម្លៃស្ថានភាពបច្ចុប្បន្នរបស់ពួកគាត់ និងការកែលម្អដែលចាំបាច់ត្រូវធ្វើ។ ជួយសម្របសម្រួលឱ្យមានការព្រមព្រៀងគ្នាលើការបែងចែកភារកិច្ច ដើម្បីសម្រេចគោលដៅទាំងនោះ ដែលគ្រួសារខ្លួនឯងចាត់ទុកថា មានភាពសមស្រប និងមានតុល្យភាព។
- ជំហានទី ៥៖ កត់ត្រាគោលដៅរបស់គ្រួសារ ដោយចែងពីជំហាននានា ដើម្បីសម្រេចគោលដៅទាំងនេះ កំណត់ថា អ្នកណាក្នុងគ្រួសារនេះ មានភារៈទទួលខុសត្រូវលើកិច្ចការអ្វីខ្លះ ដើម្បីសម្រេចគោលដៅទាំងនេះ និងលើកស្នើកំណត់ពេលវេលាសម្រាប់គោលដៅទាំងនេះ នៅលើផែនទីចក្ខុវិស័យរបស់ខ្លួន។



*រូបថតទី ៤៖ គ្រួសារមួយពិភាក្សាគោលដៅសម្រាប់គ្រួសារខ្លួន ដោយប្រើប្រាស់ផែនទីកំណត់ចក្ខុវិស័យតាមគ្រួសារ*

## ២.៣ ពិព័រណ៍ភូមិ

ពិព័រណ៍ភូមិ គឺជាឱកាសសម្រាប់គ្រួសារគំរូ(អ្នកដែលបានផ្លាស់ប្តូរជាវិជ្ជមានលើផ្នែកអាហារូបត្ថម្ភ អនាម័យ និងឥរិយាបថខាងយេនឌ័រ) ដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួន ក្នុងការអនុវត្តផែនការសកម្មភាព តាមចក្ខុវិស័យគ្រួសាររបស់ខ្លួនដោយជោគជ័យ និងអត្ថប្រយោជន៍ដែលបានពីការផ្លាស់ប្តូរទាំងនោះ ជាមួយគ្រួសារដទៃទៀតក្នុងសហគមន៍។ ការផ្លាស់ប្តូរបទពិសោធន៍បែបនេះ មានគោលដៅពង្រីកឥទ្ធិពលឱ្យកាន់តែទូលំទូលាយនៅកម្រិតសហគមន៍ តាមរយៈការលើកទឹកចិត្តដល់គ្រួសារដទៃទៀត ឱ្យចូលរួមក្នុងវគ្គស្តីពីការបង្កើតទស្សនៈវិស័យតាមគ្រួសារ និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសផ្ទះសំបែងរបស់ខ្លួន និងចែករំលែកការងារក្នុងគ្រួសារ។ ឧបសម្ព័ន្ធ ៣ បង្ហាញពីជំហានសម្រាប់សកម្មភាពបង្កើតចក្ខុវិស័យតាមគ្រួសារ។

- ជំហានទី ១៖ ជ្រើសរើសគ្រួសារគំរូ ដែលបានធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានលើផ្នែកអាហារូបត្ថម្ភ និងឥរិយាបថលើផ្នែក WASH និងការបែងចែកឱ្យមានតុល្យភាពនូវការទទួលខុសត្រូវក្នុងគ្រួសារ រវាងប្តី និងប្រពន្ធ។
- ជំហានទី ២៖ អញ្ជើញសមាជិកសហគមន៍ រួមទាំងអាជ្ញាធរមូលដ្ឋាន និងក្រុមអ្នកស្ម័គ្រចិត្តទ្រទ្រង់សុខភាព ចូលរួមក្នុងព្រឹត្តិការណ៍នេះផងដែរ។
- ជំហានទី ៣៖ ពន្យល់ពីគោលបំណងនៃពិព័រណ៍របស់គ្រួសារនោះ ដល់អ្នកចូលរួម។
- ជំហានទី ៤៖ ជួយគ្រួសារគំរូក្នុងការបង្ហាញផែនទីចក្ខុវិស័យរបស់ពួកគាត់ នៅមុន និងក្រោយអន្តរាគមន៍ និងបទពិសោធន៍របស់ពួកគាត់ ក្នុងការអនុវត្តផែនទីចក្ខុវិស័យរបស់ខ្លួន ដោយអនុញ្ញាតឱ្យមានសំណួរ និងការពិភាក្សាជាមួយសមាជិកសហគមន៍។

## ២.៤ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពរបស់គណៈកម្មការ CFR

ការបញ្ចូលស្ត្រីទៅក្នុងការដឹកនាំ និងសកម្មភាពរបស់គណៈកម្មការ CFR មានគោលដៅបង្កើនអ្នកតំណាងឱ្យសម្លេង គំនិត និងគោលបំណងរបស់ស្ត្រីក្នុងការអភិវឌ្ឍសហគមន៍ ដើម្បីធានាថា ផែនការអភិវឌ្ឍសហគមន៍មានភាពចម្រុះនិងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ ពង្រឹងសមត្ថភាព និងទំនុកចិត្តផ្ទាល់ខ្លួនរបស់ស្ត្រី ដើម្បីឈានមុខ និងទទួលយកតួនាទីដឹកនាំ ព្រមទាំង ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង CFRs ដើម្បីបង្កើនផលិតភាព និងវត្តមានផលនេសាទ។ ដំណើរការជ្រើសរើសគណៈកម្មការCFR ការបណ្តុះបណ្តាលគណៈកម្មការCFR ការរៀបចំផែនការគ្រប់គ្រងCFR នៅថ្នាក់សហគមន៍ និងដំណើរការត្រួតពិនិត្យនិងវាយតម្លៃទាំងអស់ សុទ្ធសឹងមានស្ត្រីចូលរួម។ ការធ្វើបែបនេះអាចប្រព្រឹត្តទៅបាន តាមរយៈកិច្ចសហការរវាងអ្នកអនុវត្ត និងអាជ្ញាធរមូលដ្ឋាន ដោយ៖

- បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសសមាជិកគណៈកម្មការ ដោយមានកូតាស្ត្រី ៣០% ក្រោមកិច្ចសហការជាមួយអ្នកពាក់ព័ន្ធនឹងសហគមន៍និងអាជ្ញាធរមូលដ្ឋាន ដែលផ្សព្វផ្សាយពីតួនាទីរបស់គណៈកម្មការនេះដល់សហគមន៍ទាំងមូល។
- បង្កើតគណៈកម្មការជ្រើសរើសដែលប្តេជ្ញាឱ្យមានបេក្ខភាពស្ត្រីតាមចំនួនដែលត្រូវការ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីលើកទឹកចិត្ត និងតែងតាំងស្ត្រីដែលមានសក្តានុពល ឱ្យចូលជាបេក្ខជនគណៈកម្មការ CFR។
- ផ្តល់ព័ត៌មាន លើកទឹកចិត្ត និងតែងតាំងស្ត្រី ឱ្យចូលរួមក្នុងកិច្ចប្រជុំជ្រើសរើសបេក្ខភាពគណៈកម្មការ CFR ទន្ទឹមនឹងចែករំលែកគុណសម្បត្តិនៃការចូលរួម ដែលជាការលើកទឹកចិត្តឱ្យស្ត្រីទាំងនោះចូលរួម។ ឧទាហរណ៍ស្ត្រីជាអ្នកចូលរួម ទទួលបានបទពិសោធន៍ដែលអាចពង្រឹងភាពអង់អាចរបស់ពួកគាត់ ក្នុងការទទួលយកតួនាទីដឹកនាំ ផ្សេងទៀតក្នុងសហគមន៍។

- សម្របសម្រួលដើម្បីការចូលរួមជាមួយគ្នា ទាំងស្រ្តីនិងបុរស ក្នុងការបង្កើតចក្ខុវិស័យសហគមន៍ រៀបចំផែនការសកម្មភាពដែលអាចធ្វើទៅបាន ដើម្បីដោះស្រាយបញ្ហានៃការគ្រប់គ្រងជលផលតាមវាលស្រែ។
- សម្របសម្រួលសម្រាប់ការបញ្ចូលគំនិត និងការសម្រេចចិត្តរបស់ស្រ្តី នៅគ្រប់ដំណាក់កាលនៃការគ្រប់គ្រងៈ ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ។
- វាយតម្លៃការងាររបស់គណៈកម្មការ CFR លើការចូលរួមរបស់ស្រ្តី និងចំណាត់ការតបនឹងបញ្ហារបស់ស្រ្តី ក្នុងអំឡុងពេលធ្វើការវាយតម្លៃការងារប្រចាំឆ្នាំ។

# ៣. កត្តាអំណោយផលអន្តរវិស័យ និងឧបសគ្គ

## ៣.១ កត្តាអំណោយផល

អ្នកអនុវត្តបានកំណត់អត្តសញ្ញាណកត្តាអំណោយផលជាច្រើន ដែលពាក់ព័ន្ធនឹងរាល់សកម្មភាពផ្សេងៗគ្នាលើផ្នែកអាហារូបត្ថម្ភនិងយេនឌ័រ ក្នុងការគ្រប់គ្រងជលផលតាមវាលស្រែ-សហគមន៍ស្រះជម្រកត្រីៈ ១)ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងបង្កលក្ខណៈឱ្យសហគមន៍មានភាពម្ចាស់ការ ២) ការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន និង ៣) ការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់។

### ៣.១.១ បង្កើតទំនាក់ទំនងជាមួយសហគមន៍ និងបង្កលក្ខណៈឱ្យសហគមន៍មានភាពម្ចាស់ការ

ការបង្កើតទំនាក់ទំនងល្អជាមួយសមាជិកសហគមន៍ ដូចជា ជាមួយក្រុមមនុស្សចាស់ ក្រុមដែលមានឥទ្ធិពល និងជនជាតិភាគតិច មុនពេលចាប់ផ្តើមសកម្មភាពនានា មានសារៈសំខាន់ណាស់ ក្នុងការធានាថា សកម្មភាពនានាត្រូវបានអនុវត្តដោយប្រសិទ្ធភាព។ អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលបានពន្យល់ថា ក្នុងគ្រប់សកម្មភាពទាំងអស់ ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ផ្តល់នូវការជឿទុកចិត្តរវាងអ្នកអនុវត្តនិងអ្នកចូលរួម បានលើកទឹកចិត្តឱ្យមានមានការបន្តចូលរួម និងផ្តល់ជាការលើកទឹកចិត្តឱ្យមានការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដោយសារពួកគាត់បានយល់ពីផលប្រយោជន៍ដែលអាចកើតចេញពីការចូលរួម។ ឧទាហរណ៍ តាមរយៈការបង្កើតទំនាក់ទំនងជាមួយសមាជិកសហគមន៍ មុនពេលចាប់ផ្តើមវគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ គ្រួសារនានាយល់ព្រមចូលរួមក្នុងការពិភាក្សា ធ្វើការស្វែងយល់និងកែប្រែតួនាទីយេនឌ័រដែលមានស្រាប់ ដោយសារការជឿទុកចិត្តដែលកើតមានជាមុន រវាងអ្នកសម្របសម្រួលការ បណ្តុះបណ្តាល និងសមាជិកសហគមន៍។

ការកសាងភាពម្ចាស់ការរបស់សហគមន៍ គឺជាទិដ្ឋភាពសំខាន់មួយទៀត នៃការធ្វើសមាហរណកម្មដោយជោគជ័យនូវសកម្មភាពអាហារូបត្ថម្ភ និងយេនឌ័រ ទៅក្នុងកិច្ចការជលផលតាមវាលស្រែ។ ភាពម្ចាស់ការរបស់សហគមន៍មានន័យថា សហគមន៍ ឬអ្នកដែលពាក់ព័ន្ធខាងផលប្រយោជន៍ មិនត្រឹមតែមានម្ចាស់ការលើលទ្ធផលនោះទេ ប៉ុន្តែថែមទាំង ម្ចាស់ការលើដំណើរការផងដែរ។ សម្រាប់ CFRs នេះមានន័យថា អ្នកដែលពាក់ព័ន្ធទាំងអស់នៅក្នុងជលផលតាមវាលស្រែ មានម្ចាស់ការលើ CFR ក៏ដូចជា លើដំណើរការនៃការបង្កើត ការគ្រប់គ្រង និងការធ្វើជាតំណាងឱ្យសកម្មភាពរបស់ CFRនោះផងដែរ តាមរយៈគណៈកម្មការគ្រប់គ្រង។ ភាពម្ចាស់ការរបស់សហគមន៍ អាចបង្កើតឡើងបាន ដោយការបង្កើនសមត្ថភាពសហគមន៍ ការបង្កើតទំនាក់ទំនងជាមួយអ្នកកាន់អំណាច និងការជម្រុញឱ្យមានដំណើរការនៃការទទួលស្គាល់សហគមន៍។

> “សម្រាប់ក្រុមរបស់យើង យើងប្រើឧបករណ៍ដូចគ្នា យើងប្រើវិធីដូចគ្នា ប៉ុន្តែយើងផ្តល់ការបណ្តុះបណ្តាលបន្ថែម ផ្តល់ជំនាញបន្ថែមលើការសម្របសម្រួល ផ្តល់ជំនាញបន្ថែមលើការពង្រឹងភាពអង់អាច និងរបៀបនិយាយ ពោលគឺ របៀបនិយាយជាមួយប្រជាពលរដ្ឋ និងពង្រឹងភាពអង់អាចដល់ពួកគេ ដើម្បីធ្វើការសំដែងមតិ ក្រោយមកលទ្ធផលគឺ កាន់តែជាក់លាក់ និងកាន់តែច្បាស់លាស់”។
>
> **បុរស អ្នកអនុវត្តពីអង្គការ WorldFish**

វិធីមួយដែលអ្នកអនុវត្តអាចពង្រឹងសមត្ថភាពសហគមន៍ គឺការរ៉ាប់រងតួនាទីជាអ្នកជួយសម្រួល តែមិនមែនតួ

នាទី"បង្រៀន"ឡើយនៅក្នុងវគ្គបណ្ដុះបណ្ដាលនានា។ តាមវិធីនេះ សមាជិកសហគមន៍អាចទទួលបាននូវជំនាញ ដែលត្រូវការជាចាំបាច់ ដើម្បីដោះស្រាយបញ្ហា និងធ្វើការតស៊ូមតិដោយខ្លួនឯងអំពីតម្រូវការរបស់សហគមន៍ ដូចដែលបានរៀបរាប់ដោយអ្នកអនុវត្តម្នាក់មកពីអង្គការ WorldFish នៅក្នុងសម្រង់សំដីដូចតទៅនេះ៖

ការបង្កើតទំនាក់ទំនង រវាងភាពជាអ្នកដឹកនាំក្នុងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ជាយុទ្ធសាស្ត្រសំខាន់មួយទៀត ដើម្បីបង្កើតភាពម្ចាស់ការរបស់សហគមន៍ ដោយអនុញ្ញាតឱ្យសហគមន៍ពង្រឹងទំនាក់ទំនងទាំងនេះ ដើម្បីស្វែងរកធនធាន និងដោះស្រាយបញ្ហា។ នៅក្នុងការដកស្រង់សំដីជាបន្ត អ្នកអនុវត្តម្នាក់ពីអង្គការ WorldFish បានពន្យល់ថា ដោយសារការបញ្ចូលអាហារូបត្ថម្ភនិងការលើកកម្ពស់សមភាពយេនឌ័រទៅក្នុងផែនការគ្រប់គ្រង CFR គឺជាកិច្ចការពហុវិស័យ ការតភ្ជាប់សហគមន៍ជាមួយអាជ្ញាធរពាក់ព័ន្ធនៅមូលដ្ឋាន អាចផ្ដល់នូវមធ្យោបាយគាំទ្របន្ថែម។

> ប្រសិនបើ[គណៈកម្មការ CFR] ចង់បានជំនួយឬការគាំទ្រខាងសុខភាពនិងអនាម័យ យើងអាចភ្ជាប់ពួកគេជាមួយក្រុមទ្រទ្រង់សុខភាពភូមិ ឬមណ្ឌលសុខភាពភូមិ។ ប្រសិនបើពួកគាត់ចង់បានការគាំទ្របច្ចេកទេសដែលទាក់ទងនឹងជលផល យើងអាចនាំពួកគាត់[គណៈកម្មការCFR] មកជួបរដ្ឋបាលជលផល។ យើងគ្រាន់តែបង្ហាញ[គណៈកម្មការ CFR] នូវអ្វីដែលជាដំណោះស្រាយ ដែលពួកគេគួរស្វែងរក ដើម្បីអាចអនុវត្តផែនការ [CFR] របស់ខ្លួន។ ( បុរស អ្នកអនុវត្តពីអង្គការ WorldFish)

លើសពីនេះ ការទទួលស្គាល់សហគមន៍ ទាំងពីសំណាក់សមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋាន មានសារៈសំខាន់ណាស់ នៅក្នុងគ្រប់សកម្មភាព។ វាអាចជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការជួយសម្រួលដល់ការផ្សព្វផ្សាយចំណេះដឹងដល់សមាជិកដទៃទៀតក្នុងសហគមន៍ លើកទឹកចិត្ត និងជំរុញឱ្យមានការកែលម្អប្រកបដោយនិរន្តរភាព លើកិច្ចការអាហារូបត្ថម្ភ និងឥរិយាបថខាងផ្នែកយេនឌ័រ។

> យើងបង្កើតចក្ខុវិស័យ[តាមគ្រួសារ] បន្ទាប់មកនៅពេលអ្នកសម្រេចតាមចក្ខុវិស័យនោះហើយ [គ្រួសារគំរូ] ក្លាយជាធនធានមនុស្ស ដែលអាចចែករំលែកបទពិសោធន៍របស់ខ្លួន ដល់អ្នកជិតខាងក្នុងភូមិទាំងមូល។ បន្ទាប់មកយើងក៏សូមអញ្ជើញមន្ត្រីរដ្ឋាភិបាល ដូចជា មេឃុំ មកប្រគល់វិញ្ញាបនបត្រលើកទឹកចិត្តដល់គ្រួសារនេះ។ បន្ទាប់មក [គ្រួសារគំរូ]ដាក់តាំងវិញ្ញាបនបត្រនោះនៅផ្ទះរបស់ខ្លួន - ពួកគេមានមោទនភាពចំពោះការងាររបស់ខ្លួន។ នៅពេលពួកគេមានមោទនភាពចំពោះការងាររបស់ខ្លួន ពួកគាត់ចង់បង្ហាញពីមោទនភាពមួយកម្រិតថែមទៀត ពោលគឺ កម្រិតខ្ពស់មួយទៀតនៃសមិទ្ធផល។ ដូច្នេះ នោះគឺជាលទ្ធផលនៃចក្ខុវិស័យសហគមន៍ និងពិព័រណ៍តាមគ្រួសារ។ ( បុរស អ្នកអនុវត្តមកពីអង្គការ WorldFish)

### ៣.១.២ បង្កើតនិងរក្សាទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នរដ្ឋាភិបាល

រវាងសកម្មភាពទាំងអស់ ការបង្កើតទំនាក់ទំនង និងការបន្តចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន ជាអាទិ៍ រដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការកុមារនិងស្ត្រី អភិបាលខេត្ត អភិបាលស្រុក មេឃុំនិងមេភូមិ គឺជាផ្នែករួម។ ឧទាហរណ៍ កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន គឺជាជំហានដ៏សំខាន់ដំបូង សម្រាប់ការបញ្ចូលស្ត្រី និងការពាក់ព័ន្ធរបស់ស្ត្រីនៅក្នុងការដឹកនាំ CFR។ អាជ្ញាធរមូលដ្ឋានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យស្ត្រីនៅក្នុងសហគមន៍បានចូលរួមក្នុងកិច្ចប្រជុំជ្រើសរើសបេក្ខភាពគណៈកម្មការ CFR។ អាជ្ញាធរមូលដ្ឋានបានលើកទឹកចិត្តស្ត្រី ឱ្យស្ម័គ្រចិត្តចូលរួមក្នុងគណៈកម្មការ CFR ព្រមទាំងបានតែងតាំងស្ត្រីដែលពួកគេយល់ថាសមស្រប ឱ្យចូលរួមក្នុង គណៈកម្មការ CFR។

ការបន្តចូលរួមជាមួយក្រុមប្រឹក្សាឃុំ ក៏មានសារៈសំខាន់ផងដែរ ជាពិសេសដើម្បីនិរន្តរភាពនៃសកម្មភាព។ ឧទាហរណ៍អំពីការចូលរួមរបស់ក្រុមប្រឹក្សាឃុំ រួមមាន ការបញ្ចុះបញ្ចូលដើម្បីដាក់បញ្ចូលសកម្មភាពអាហារូបត្ថម្ភ និងយេនឌ័រទៅក្នុងកម្មវិធីវិនិយោគឃុំ និងដើម្បីបន្តវិភាជន៍ថវិកាឃុំសម្រាប់អនុវត្តសកម្មភាពទាំងនេះបន្ទាប់ពីគម្រោងចប់។

យើងគិតថា ដើម្បីឱ្យការបណ្តុះបណ្តាលអំពីអាហារូបត្ថម្ភ និងអនាម័យ និងដំណើរការផ្សព្វផ្សាយដល់អ្នកថែទាំកុមារមាននិរន្តរភាពសម្រាប់រយៈពេលវែង ប្រតិបត្តិករគម្រោងត្រូវសហការជិតស្និទ្ធជាមួយជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ(CWCC)នៃក្រុមប្រឹក្សាឃុំ ជាមួយគណៈកម្មការកិច្ចការស្ត្រីនិងកុមារនៃក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាជាតិដើម្បីស្ត្រីនិងកុមារ ដើម្បីចូលរួមក្នុងមុខងាររបស់ពួកគេ ក្នុងគោលដៅលើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំ ជាពិសេស CWCC ដែលមានមុខងារ និងវិភាជន៍ថវិកាឃុំ សម្រាប់ដំណើរការអភិវឌ្ឍអ្នកថែទាំកុមារ។ (បុរស អ្នកអនុវត្តនៃអង្គការមិនរដ្ឋាភិបាលក្នុងស្រុក)

### ៣.១.៣ សមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់

ការបញ្ចូលសកម្មភាពគម្រោងទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់ ដូចជា ក្រុមទ្រទ្រង់សុខភាពភូមិ(VHSG) និងមណ្ឌលសុខភាព មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការបញ្ចូលសកម្មភាពអាហារូបត្ថម្ភនិងយេនឌ័រឱ្យមានប្រសិទ្ធភាព។ ធ្វើការនៅក្នុងរចនាសម្ព័ន្ធទាំងនេះអាចអនុញ្ញាតឱ្យមានការប្រើប្រាស់បណ្តាញសំខាន់មួយ សម្រាប់បញ្ជូនសារ និងការសម្របសម្រួលជាមួយគ្រួសារនានាក្នុងសហគមន៍ ការសង្កេតនិងតាមដានជាបន្តបន្ទាប់អំពីឥរិយាបថខាងអាហារូបត្ថម្ភ និងការអនុវត្តរបស់គ្រួសារនានាតាមផែនទីចក្ខុវិស័យរបស់ខ្លួន និងសង្គតិភាពនៃការបញ្ជូនសារទៅអ្នកអនុវត្តផ្សេងៗទៀត។ សម្រាប់ការបណ្តុះបណ្តាលអំពីអាហាររូបត្ថម្ភ និងអំពី WASH គម្រោងនេះប្រើប្រាស់ផ្ទាំងរូបភាពពីក្រសួងសុខាភិបាល ស្តីពីការបំបៅដោះកូននិងការចិញ្ចឹមកូន ព្រមទាំងខ្សែអាត់សំលេង និងវីដេអូពីគម្រោង NOURISH ដែលនាំមុខដោយអង្គការសង្គ្រោះកុមារ និងអង្គការយូនីសេហ្វ ប៉ុន្តែឧបករណ៍ទាំងនេះត្រូវបានកែសម្រួលដោយបញ្ចូលសារជាក់លាក់អំពីត្រី តាមរយៈការអនុវត្តបង្ហាញ និងខ្សែវីដេអូ។ លើសពីនេះ ការធ្វើសមាហរណកម្មនេះបានអនុញ្ញាតឱ្យមានការស្រង់មតិយោបល់ត្រឡប់មកវិញ និងយន្តការដោះស្រាយបញ្ហា រវាងអ្នកអនុវត្តនិងសមាជិកសហគមន៍ដូចដែលបានពិពណ៌នានៅក្នុងសម្រង់សំដីខាងក្រោមនេះ៖

លើសពីនេះ ការធ្វើសមាហរណកម្មស្ថាប័ននានាដែលបានបង្កើតឡើងនៅក្រោមគម្រោងនេះ ទៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់នៃរដ្ឋាភិបាល មានសារៈសំខាន់ជាសារវន្ត ចំពោះនិរន្តរភាពនិងគណនេយ្យភាពនៃលទ្ធផលលើផ្នែកអាហារូបត្ថម្ភនិងយេនឌ័រ។ ឧទាហរណ៍ ការផ្សារភ្ជាប់គណៈកម្មការ CFR ទៅក្នុងដំណើរការរៀបចំផែនការរបស់ក្រុមប្រឹក្សាឃុំ អនុញ្ញាតឱ្យពួកគាត់បញ្ចូលផែនការCFR ទៅក្នុងផែនការរបស់រដ្ឋាភិបាល ប៉ុន្តែក៏ផ្តល់នូវរចនាសម្ព័ន្ធផ្លូវការមួយ ដើម្បីត្រួតពិនិត្យនិងតាមដានវឌ្ឍភាពនៃផែនការរបស់សហគមន៍ផងដែរ។



*រូបថតទី ៥៖ កុមារកំពុងញ៉ាំអាហារដែលរៀបចំដោយប្រើប្រាស់ត្រីរកបានក្នុងមូលដ្ឋាន នៅក្នុងពេលអនុវត្តបង្ហាញអំពីការចំអិនអាហារ។*

## ៣.២ ឧបសគ្គ

ចំពោះសកម្មភាពអាហារូបត្ថម្ភនិងយេនឌ័រ មានឧបសគ្គអន្តរវិស័យខ្លះៗ ដែលអ្នកអនុវត្តគម្រោងបានកំណត់ឃើញ៖១)អសមធម៌នៃនិយាមយេនឌ័រ ២)កម្រិតទាបនៃអក្ខរកម្ម និង៣)ចំណាកស្រុកញឹកញាប់ដើម្បីរកការងារធ្វើ។

### ៣.២.១ វិសមភាពជាទូទៅនៃនិយាមយេនឌ័រ

នៅទូទាំងវគ្គបណ្តុះបណ្តាលអ្នកថែទាំកុមារ វគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ និងការបញ្ចូលស្ត្រីទៅក្នុងគណៈកម្មការ CFR និយាមយេនឌ័រដែលមានស្រាប់ (ដូចជា ការយល់ថា ស្ត្រីត្រូវរ៉ាប់រងការទទួលខុសត្រូវចំពោះតួនាទីក្នុងផ្ទះ ហើយបុរសទទួលខុសត្រូវចំពោះតួនាទីនៅក្រៅផ្ទះ) ត្រូវគេមើលឃើញថា ជាឧបសគ្គចំពោះការអនុវត្តសកម្មភាពទាំងនេះឱ្យមានប្រសិទ្ធភាព។ ការចូលរួមកម្រិតទាបនៃបុរស ត្រូវបានគេសង្កេតឃើញ ទាំងក្នុងវគ្គបណ្តុះបណ្តាលអ្នកថែទាំកុមារ និងក្នុងវគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ ដោយសារសហគមន៍និងគ្រួសារនានាយល់ថា អាហារូបត្ថម្ភ និងការបង្កើតចក្ខុវិស័យតាមគ្រួសារ គឺជាការទទួលខុសត្រូវរបស់ស្ត្រី ហើយការរកប្រាក់ចំណូល គឺជាការទទួលខុសត្រូវរបស់បុរស។

> "ភាគច្រើនមានតែស្ត្រីទេដែលបានចូលរួមក្នុងវគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ ដោយសារបុរសគិតថា វាជាការងាររបស់ស្ត្រី ហើយបុរសត្រូវចេញទៅធ្វើការនៅខាងក្រៅ"។
>
> - **ស្ត្រី អ្នកអនុវត្តពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**

កម្រិតទាបនៃការចូលរួមរបស់បុរសនៅក្នុងវគ្គចក្ខុវិស័យតាមគ្រួសារ ក៏មានឥទ្ធិពលដោយប្រយោលដល់ការចូលរួមរបស់ស្ត្រីក្នុងការដឹកនាំគណៈកម្មការCFRផងដែរ។ អ្នកអនុវត្តបានពន្យល់ថា ស្ត្រីដែលមិនអាចចូលរួមក្នុងគណៈកម្មការ CFR ភាគច្រើនបានផ្តល់ហេតុផលដូចជា៖ ពួកគាត់ជាប់រវល់ ទទួលខុសត្រូវលើកិច្ចការផ្ទះ ប្តីរបស់គាត់មិនអនុញ្ញាត ពួកគេបារម្ភថាប្តីអាចនឹងប្រច័ណ្ឌ។

អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលក៏បានពន្យល់ផងដែរថា ស្ត្រី"មិនក្លាហាន"ក្នុងការចូលរួមក្នុងគណៈកម្មការដឹកនាំ CFR ដោយអ្នកខ្លះពោលថា មានការលើកទឹកចិត្តត្រឹមតិចតួចពីស្វាមី សមាជិកគ្រួសារ និងសហគមន៍។ សូម្បីនៅពេលដែលស្ត្រីត្រូវបានបញ្ចូលក្នុងគណៈកម្មការ CFR ហើយក៏ដោយ ពួកគាត់ច្រើនរ៉ាប់រងតួនាទីដែលមិនពាក់

ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្ត ដូចជា អ្នករក្សាឯកសារ ឬអ្នកធ្វើកំណត់ហេតុ។ នេះអាចជាការបង្ហាញពីកង្វះបរិយាកាសអំណោយផលសម្រាប់ស្ត្រីដើម្បីចូលរួមក្នុងតួនាទីដឹកនាំ ដោយសារតែវិសមភាពសម្រាប់ស្ត្រីក្នុងការទទួលបានការសិក្សា និងដោយសារស្ត្រីយល់ឃើញថា ពួកគាត់មិនសមនឹងតំណែងដឹកនាំឡើយ។

ដូច្នេះ អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់អនុសាសន៍ដែលផ្តោតលើសកម្មភាពបង្កើនការយល់ដឹងអំពីយេនឌ័រ ដូចជា ការពិភាក្សាអំពីខ្លឹមសារ និងសារៈសំខាន់នៃសមភាពយេនឌ័រ ការយល់ឃើញអំពីតួនាទីយេនឌ័រ និងការប៉ះពាល់នៃតួនាទីទាំងនោះចំពោះគ្រួសារនិងសហគមន៍។ ទោះយ៉ាងណាក៏ដោយ ទន្ទឹមនឹងបង្កើនការយល់ដឹងពីយេនឌ័រ ប្រការសំខាន់គឺត្រូវ ដោះស្រាយភាពចាំបាច់ដើម្បីកសាងសមត្ថភាពរបស់ស្ត្រី មិនត្រឹមតែសមត្ថភាពដឹកនាំ និងទំនុកចិត្តលើការងាររបស់ខ្លួនផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការងារជលផលតាមវាលស្រែផងដែរ ដើម្បីឱ្យពួកគាត់មានទំនុកចិត្ត និងអាចរួមចំណែកដល់ការគ្រប់គ្រង CFR ប្រកបដោយអត្ថន័យ។

#### ៣.២.២ ការយល់ថា អ្នកចូលរួមមានកម្រិតទាបនៃការចេះអក្សរ និងការធ្វើចំណាកស្រុកជាញឹកញាប់

អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលជួបការលំបាកក្នុងការផ្តល់វគ្គការបណ្តុះបណ្តាល ដោយសារពួកគាត់យល់ឃើញថា អ្នកចូលរួមខ្លះចេះអក្សរកម្រិតទាបពេក។ ប្រការនេះធ្វើឱ្យអ្នកចូលរួម លំបាកក្នុងការស្វែងយល់អំពីសញ្ញាណនៃអាហារូបត្ថម្ភ ការគូរ និងសរសេរផែនទីចក្ខុវិស័យតាមគ្រួសារ និងគិតស្រមៃអំពីស្ថានភាពគ្រួសារខ្លួនទៅអនាគត។ ដើម្បីសម្របតាមស្ថានភាពនេះ អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលផ្តោតលើការប្រើប្រាស់ឧបករណ៍ចក្ខុទស្សន៍និងសោតទស្សន៍ ដូចជា ផ្ទាំងរូបភាពនិងវីដេអូ ព្រមទាំងផ្តល់ឧទាហរណ៍ពីបទពិសោធន៍ផ្ទាល់របស់ខ្លួន។ អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលក៏បានពន្យល់ផងដែរថា កម្រិតទាបនៃចេះអក្សរក្នុងចំណោមស្ត្រីមួយចំនួនបានរារាំងពួកគាត់ ពីការចូលរួមក្នុងគណៈកម្មការ CFR ព្រោះតំណែងខ្លះត្រូវការចំណេះអាននិងសរសេរ។

បញ្ហាប្រឈមមួយទៀតដែលពិពណ៌នាដោយអ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលគឺ អ្នកចូលរួមបានធ្វើចំណាកស្រុកជាញឹកញាប់។ បុរស និងពេលខ្លះស្ត្រីផងដែរ នៃគ្រួសារដែលចូលរួមក្នុងការងារសហគមន៍ តែងធ្វើចំណាកស្រុកទៅទីក្រុង ឬប្រទេសជាប់ព្រំដែន ដែលធ្វើឱ្យមានការលំបាក ទាំងក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងការធានាឱ្យមានការអនុវត្តសកម្មភាពអាហារូបត្ថម្ភ និងចំណេះដឹងអំពីយេនឌ័រ។ ជាពិសេស អ្នកអនុវត្តពីអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានពោលថា ពួកគាត់មិនអាចចាត់ចែងការជួបជុំគ្រួសារជាមួយទាំងប្តីនិងប្រពន្ធបានទេ ដោយសារប្តីតែងធ្វើចំណាកស្រុកដើម្បីស្វែងរកការងារ។ ទោះបីអ្នកអនុវត្តពីអង្គការមិនមែនរដ្ឋាភិបាលបានសម្រួល ដោយការលើកទឹកចិត្តឱ្យស្ត្រីជាភរិយាចែករំលែកចំណេះដឹងដែលបានរៀនពីវគ្គបណ្តុះបណ្តាលជាមួយស្វាមីក៏ដោយ ការតាមដាន និងការធានាឱ្យមានការចែករំលែកបែបនេះ គឺជាការលំបាក។

## ៤. សកម្មភាពអំណោយផល និងឧបសគ្គ

### ៤.១ ការបណ្តុះបណ្តាលដល់អ្នកថែទាំកុមារ និងការបង្កើតចក្ខុវិស័យតាមគ្រួសារ

#### ៤.២.១ សកម្មភាពអំណោយផល

គ្រួសារនានាទំនងជាឆ្លើយតបទៅនឹងការបណ្តុះបណ្តាល និងយកមេរៀនដែលពួកគេបានពីវគ្គបណ្តុះបណ្តាលទៅអនុវត្ត នៅពេលអ្នកអនុវត្តពន្យល់យ៉ាងល្អិតល្អន់អំពីគុណសម្បត្តិនិងអត្ថប្រយោជន៍នៃសកម្មភាពទាំងនោះ។ ឧទាហរណ៍ អ្នកអនុវត្តបានកត់សម្គាល់ថា ជួនកាលអ្នកចូលរួមមានការពិបាកយល់សកម្មភាពបង្កើតចក្ខុវិស័យតាមគ្រួសារ ប៉ុន្តែក្រោយពីបានផ្តល់ឧទាហរណ៍ និងពន្យល់ថា ការអនុវត្តផែនទីចក្ខុវិស័យតាមគ្រួសារទាំងនោះ នឹងមានប្រយោជន៍សម្រាប់សុខភាព និងភាពសុខដុមរមនានៃគ្រួសារ ទើបអ្នកចូលរួមទាំងនោះអនុវត្តតាម។

ការផ្ទេរចំណេះដឹងបន្តពីអ្នកចូលរួម បន្តទៅសមាជិកដទៃក្នុងគ្រួសារ ទៅអ្នកជិតខាង និងសមាជិកដទៃក្នុងសហគមន៍ ក៏ជួយពង្រីកឥទ្ធិពលនៃសកម្មភាពអាហារូបត្ថម្ភនិងយេនឌ័រដោយជោគជ័យផងដែរ។

គន្លឹះនៃជោគជ័យក្នុងការបណ្តុះបណ្តាលអ្នកថែទាំកុមារគឺ អ្នកថែទាំកុមារបានយល់ច្បាស់អំពីប្រធានបទនៃមេរៀន យកចំណេះដឹងពីវគ្គនេះទៅអនុវត្តក្នុងគ្រួសាររបស់ខ្លួន និងចែករំលែកដល់អ្នកជិតខាង។ - (បុរស អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)

ការបង្កើតចក្ខុវិស័យតាមគ្រួសារ ជាពិសេសនៅពេលគ្រួសារទាំងមូល(ប្តីនិងប្រពន្ធ)ចូលរួមអនុវត្តលំហាត់នេះទំនងជានាំមកនូវផលវិជ្ជមាន។



*រូបថតទី ៦៖ ប្តី និងប្រពន្ធ ថែទាំច្បារដំណាំជាមួយគ្នា។*

## ៤.១.៣ យុទ្ធសាស្ត្របណ្តុះបណ្តាលដែលមានប្រសិទ្ធភាព

អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាល បានពិពណ៌នាអំពីយុទ្ធសាស្ត្រ និងឧបករណ៍បណ្តុះបណ្តាលមួយចំនួនដែលមានប្រសិទ្ធភាពខ្ពស់៖

- ការទទួលស្គាល់៖ ការទទួលស្គាល់ជាសាធារណៈ ឬជាឯកជន នូវសមិទ្ធផលរបស់គ្រួសារ (ទាំងផ្លូវការ ឬមិនផ្លូវការ) ជាពិសេសដោយអាជ្ញាធរមូលដ្ឋានអំពីការកែលំអក្នុងគ្រួសារ និងលើកទឹកចិត្តដល់គ្រួសារដទៃឱ្យចូលរួម។
- តាមដានបន្ត៖ ធ្វើទស្សនកិច្ចជាប្រចាំ និងទៀងទាត់តាមគ្រួសារ ដើម្បីពិនិត្យមើលវឌ្ឍនភាព និងណែនាំឱ្យអនុវត្តសកម្មភាពទាំងនោះឡើងវិញ តាមការចាំបាច់។
- ការអនុវត្តបង្ហាញជាក់ស្តែង៖ គម្រោងនេះបានផ្តល់នូវការអនុវត្តបង្ហាញដោយផ្ទាល់ អំពីរបៀបចំអិនអាហារដែលមានជីវជាតិ ដោយប្រើប្រាស់ត្រីដែលរកបានក្នុងមូលដ្ឋាន។
- ឧបករណ៍សោតទស្សន៍និងចក្ខុទស្សន៍៖ ផ្ទាំងរូបភាព និងសន្លឹកព័ត៌មាន ដែលភាគច្រើនបង្ហាញតាមរយៈរូបភាពជួយឱ្យងាយយល់។ ខ្សែអាត់សំឡេងនិងវីដេអូ ជាមធ្យោបាយងាយស្រួលក្នុងការផ្សព្វផ្សាយព័ត៌មានដល់សមាជិកទូទៅ។ ពួកគេក៏អាចប្រើប្រាស់វីដេអូជាជំនួយក្នុងសកម្មភាពអនុវត្តបង្ហាញផងដែរ។ ឧទាហរណ៍ ការអនុវត្តបង្ហាញ អាចតម្រូវឱ្យអ្នកចូលរួមចំណាយពេលវែង ដូច្នេះការប្រើប្រាស់វីដេអូដែលបានថតទុកមុន អ្នកអនុវត្តអាចសម្រេចថា តើត្រូវផ្តោតលើទិដ្ឋភាពណាខ្លះ និងព័ត៌មានណាខ្លះដែលត្រូវផ្តល់បន្ថែម។
- ប្រព័ន្ធព័ត៌មានសង្គម៖ ឧទាហរណ៍អ្នកអនុវត្តខ្លះបង្កើតក្រុមអ្នកចូលរួមក្នុងហ្វេសប៊ុក ឬអ្នកភ្ជាប់ទំនាក់ទំនងដោយការផ្ញើសារតាមហ្វេសប៊ុក ដើម្បីចែករំលែកវីដេអូសម្រាប់ការបណ្តុះបណ្តាល។

អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលក៏បានកត់សម្គាល់ផងដែរថា សកម្មភាពចូលរួម ដូចជាការអនុវត្តបង្ហាញអំពីការចំអិនអាហារ មានឥទ្ធិពលបំផុត។ ក្នុងអំឡុងនៃវគ្គបង្កើតចក្ខុវិស័យតាមគ្រួសារ ស្វាមីនិងភរិយាអាចយល់និងរៀបចំផែនការអនាគតគ្រួសាររបស់ខ្លួន នៅពេលពួកគាត់គូសផែនទីចក្ខុវិស័យសម្រាប់គ្រួសារខ្លួនដោយខ្លួនឯង៖

"នៅពេលពួកគាត់គូសផែនទីចក្ខុវិស័យដោយខ្លួនឯង ពួកគាត់នឹងដឹងច្បាស់ថា ពួកគាត់ត្រូវធ្វើអ្វីក្នុងពេលអនាគត។ ពួកគាត់ដឹងថា អ្វីជាកិច្ចការអាទិភាពដែលពួកគាត់ត្រូវធ្វើឱ្យហើយមុន"។ (បុរស អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)



*រូបថតទី ៧៖ អ្នកអនុវត្តម្នាក់មកពីអង្គការមិនមែនរដ្ឋាភិបាល ណែនាំពីសកម្មភាពការចំអិនអាហារ ដោយប្រើប្រាស់ត្រី និងបន្លែចម្រុះ*

### ៤.១.៤ ឧបសគ្គ និងអនុសាសន៍

អ្នកអនុវត្តនៅទូទាំងខេត្តទាំង៤ បានកំណត់អត្តសញ្ញាណឧបសគ្គមួយចំនួននៅក្នុងការអនុវត្ត ។ អ្នកអនុវត្តស្ទើរទាំងអស់ មកពីអង្គការមិនមែនរដ្ឋាភិបាល បានរៀបរាប់ពី ការចំណាយពេលដ៏ច្រើន ដើម្បីបញ្ចប់វគ្គបណ្តុះបណ្តាលទាំងអស់ ដែលធ្វើឱ្យអ្នកចូលរួមលំបាកក្នុងការទទួលយកយកព័ត៌មានយ៉ាងច្រើនបែបនេះ។ វគ្គនីមួយៗត្រូវចំណាយពេលប្រហែលកន្លះថ្ងៃ ភាគច្រើនដោយសារត្រូវចំណាយពេលធ្វើម្ហូប ជាមួយការណែនាំបច្ចេកទេសមានរយៈពេលរហូតដល់ពីរម៉ោង។ អ្នកអនុវត្តពីអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់អនុសាសន៍ឱ្យមានវគ្គបណ្តុះបណ្តាលខ្លីៗនិងញឹកញាប់ជាងនេះ (ប៉ុន្តែ ពួកគាត់ពោលថា វាអាស្រ័យលើលទ្ធភាពខាងថវិកា និងពេលវេលារបស់បុគ្គលិក) និងការសង្ខេបខ្លីអំពីវគ្គបណ្តុះបណ្តាលកន្លងមក មុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាលនីមួយៗ។ លើសពីនេះ ដើម្បីជម្នះបញ្ហាប្រឈមបណ្តាលពីអត្រាទាបនៃការចេះអក្សរក្នុងចំណោមអ្នកចូលរួម អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់អនុសាសន៍ឱ្យមានការផ្តល់សារសាមញ្ញៗ ដែលអាចឱ្យអ្នកចូលរួម"ងាយចងចាំ"។ (ស្ត្រី អ្នកអនុវត្តមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)

អ្នកអនុវត្តមួយចំនួនមកពីអង្គការមិនមែនរដ្ឋាភិបាល បានលើកឡើងពីតម្រូវការដើម្បីធ្វើបច្ចុប្បន្នភាពខ្លឹមសារក្នុងសៀវភៅណែនាំការបណ្តុះបណ្តាល។ ឧទាហរណ៍ គម្រោងលើកទឹកចិត្តដល់គ្រួសារនានាឱ្យញ៉ាំអាហារ យ៉ាងតិច ៣ ក្រុម ក្នុងមួយថ្ងៃៗ ប៉ុន្តែបច្ចុប្បន្ន រដ្ឋាភិបាលណែនាំឱ្យទទួលទានអាហារ ៥ ក្រុមផ្សេងគ្នាក្នុងមួយថ្ងៃៗ។

## ៤.២ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនៃគណៈកម្មការ CFR

### ៤.២.១ កត្តាអំណោយផល

ដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងការដឹកនាំរបស់គណៈកម្មាធិការCFR គេត្រូវមានកត្តាមួយចំនួនជាចាំបាច់។ ទីមួយការលើកទឹកចិត្តពីគ្រួសារ សហគមន៍ និងអាជ្ញាធរមូលដ្ឋានដែលស្ត្រីនោះរស់នៅ អាចបង្កើនលទ្ធភាពដែលស្ត្រីនឹងអាចចូលរួមក្នុងគណៈកម្មការគ្រប់គ្រង CFR។

> ដើម្បីឱ្យស្ត្រីអាចបន្តការចូលរួមក្នុងការងារនៃគណៈកម្មាធិការគ្រប់គ្រង CFR សម្រាប់រយៈពេលវែង ត្រូវមាន៖ ១)ការគាំទ្រនិងលើកទឹកចិត្តពីស្វាមីនិងសមាជិកគ្រួសារ ២)ការចូលរួមនិងលើកទឹកចិត្តពីអាជ្ញាធរពាក់ព័ន្ធដូចជាអាជ្ញាធរមូលដ្ឋាននិងចាស់ទុំក្នុងសហគមន៍។ (បុរស អ្នកអនុវត្តពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក)

លើសពីនេះ ពេលវេលានិងការជឿជាក់លើខ្លួនឯងរបស់ស្ត្រី គឺជាកត្តាសំខាន់ ដើម្បីស្ត្រីអាចចូលរួមក្នុងគណៈកម្មការ CFR។ ចំពោះស្ត្រី ដែលមានការចែករំលែកកិច្ចការក្នុងគ្រួសារ ពួកគាត់មានពេលច្រើនសម្រាប់សកម្មភាពបង្កើតប្រាក់ចំណូល និងការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាព។

> " យើងអាចឃើញលទ្ធផលខ្លះផ្អែកលើបទពិសោធន៍កន្លងមក យើងអាចឃើញគ្រួសារខ្លះចេះបែងចែកភារកិច្ច។ ដោយសារតែការបំពេញភារកិច្ចរួមគ្នា ស្ត្រីមានពេលវេលាដើម្បីរកប្រាក់ចំណូលខ្លះ។ នៅពេលស្ត្រីមានប្រាក់ចំណូលកាន់តែខ្ពស់ ពួកគាត់ក៏ចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយចំនួនដែលរៀបចំដោយគម្រោងរបស់យើង ពួកគាត់អាចត្រូវបានជ្រើសរើសជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសជាសមាជិកគណៈកម្មការ ព្រោះបច្ចុប្បន្ន ពួកគាត់មានទំនុកចិត្ត ហើយឥឡូវពួកគាត់ក៏មានប្រាក់ចំណូលខ្លះៗ ហើយពួកគាត់ក៏បានការទទួលស្គាល់ថា ពួកគាត់គឺជាអ្នកដែលអាចចែករំលែកតួនាទីនិងការទទួលខុសត្រូវ មិនត្រឹមតែនៅកម្រិតគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែនៅកម្រិតខ្ពស់ជាងនេះផងដែរ។"
>
> **បុរស អ្នកអនុវត្តពីអង្គការ WorldFish**

ការជឿជាក់លើខ្លួនឯងរបស់ស្ត្រីទាំងនេះ នៅជុំវិញភាពជាអ្នកដឹកនាំនៅក្នុងសហគមន៍ ក៏បានប្រសើរឡើងផងដែរ ហើយពួកគាត់មានអារម្មណ៍ថា ពួកគាត់មានរបរ និងការពង្រឹងភាពអង់អាច ដើម្បីចូលរួមជាមួយថ្នាក់ដឹកនាំក្នុងគណៈកម្មការ CFR។ ការបង្កើនទំនុកចិត្តរបស់ស្ត្រីលើខ្លួនឯងក្នុងភាពជាអ្នកដឹកនាំ ក៏អនុញ្ញាតឱ្យសមាជិកសហគមន៍ទទួលស្គាល់សមត្ថភាពនិងសក្តានុពលភាពរបស់ស្ត្រីជាអ្នកដឹកនាំរបស់ពួកគេផងដែរ។ ឧទាហរណ៍ ស្ត្រីម្នាក់ដែលជាសមាជិកគណៈកម្មការ CFR ត្រូវបានទទួលឱ្យធ្វើការជាជំនួយការក្រុមប្រឹក្សាឃុំ មួយផ្នែកដោយសារតែសហគមន៍នេះ និងក្រុមប្រឹក្សាឃុំ មើលឃើញភាពដឹកនាំ និងសមត្ថភាពការងាររបស់គាត់ក្នុងនាមជាសមាជិកគណៈកម្មការ CFR៖

> នៅពេលខ្ញុំបានចូលរួមជាសមាជិកគណៈកម្មការ CFR ខ្ញុំបង្ហាញពីសមត្ថភាពនិងការទទួលខុសត្រូវ និងភាពស្មោះត្រង់របស់ខ្ញុំ ចំពោះសហគមន៍និងអាជ្ញាធរមូលដ្ឋាន។ នៅពេលមួយនោះ ក្រុមប្រឹក្សាឃុំនេះត្រូវការអ្នកជំនួយការម្នាក់ ដូច្នេះខ្ញុំបានដាក់ពាក្យសម្រាប់តំណែងនេះ។ ដោយសារក្រុមប្រឹក្សាឃុំធ្លាប់ស្គាល់ខ្ញុំពីមុន និងស្គាល់ការងាររបស់ខ្ញុំនៅក្នុងសហគមន៍ ក៏ដូចជា សមត្ថភាពខ្ញុំផងដែរ ដូច្នេះក្រោយមកក្រុមប្រឹក្សាឃុំបានជ្រើសយកខ្ញុំជាជំនួយការក្រុមប្រឹក្សាឃុំ។ (ស្ត្រី សមាជិកគណៈកម្មការ CFR)

បន្ថែមពីលើការបញ្ចូល និងមានស្ត្រីជាតំណាងក្នុងគណៈកម្មការ CFR ហើយ ប្រការសំខាន់គឺ ត្រូវធានាថាស្ត្រីមានសមត្ថភាព ទឹកចិត្ត និងពេលវេលា ដើម្បីរួមចំណែកដល់គណៈកម្មការ CFR ប្រកបដោយប្រសិទ្ធភាព ហើយការសម្រេចចិត្តរបស់ពួកគាត់ ត្រូវបានគោរព និងពិចារណានៅក្នុងគណៈកម្មការ CFR របស់ពួកគេ។ ការគាំទ្រដល់ដំណើរការជ្រើសរើសដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះមានការបង្ហាញឱ្យស្ត្រីដឹងពីជំនាញ សមត្ថភាព ការទទួលខុសត្រូវ និងពេលវេលាដែលជាលក្ខខណ្ឌចាំបាច់សម្រាប់តំណែងក្នុងគណៈកម្មការ CFR តាមរយៈវគ្គតំរង់ទិសជាមុនដល់សហគមន៍ គឺជាវិធីមួយក្នុងការជ្រើសរើសស្ត្រី ដែលមានឆន្ទៈ និងសមត្ថភាពក្នុងការគាំទ្រដល់ការគ្រប់គ្រង CFRs ប្រកបដោយអត្ថន័យ។ បន្ទាប់ពីបានជ្រើសរើសពួកគេចូលក្នុងគណៈកម្មការ CFR ប្រការចាំបាច់ផងដែរគឺ ត្រូវបន្តគាំទ្រដល់ស្ត្រីជាសមាជិកាគណៈកម្មការ និងកសាងសមត្ថភាពដឹកនាំ ដោយផ្តោតលើជំនាញដែលពួកគាត់ចង់បាន។



*រូបថតទី ៨៖ ស្ត្រីសមាជិកាគណៈកម្មការ CFR មួយរូប ដែលគ្រប់គ្រង និងដឹកនាំការកៀរគរមូលនិធិសម្រាប់ CFR របស់ពួកគាត់*

# សេចក្ដីសន្និដ្ឋាន

ការបញ្ជូលអន្តរាគមន៍លើផ្នែកអាហារូបត្ថម្ភ និងយេនឌ័រ រួមជាមួយសកម្មភាពគ្រប់គ្រងជលផលតាមវាលស្រែ មានសក្តានុពលក្នុងការបង្កើនលទ្ធផលខាងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាពិសេស ក្នុងចំណោមស្ត្រី និងកុមារ។ កត្តាអំណោយផលនានាដល់ការអនុវត្តដោយជោគជ័យនូវសកម្មភាពទាំងនេះ ដែលអ្នកអនុវត្តភាគច្រើនបានកំណត់ឃើញ ផ្ដោតលើភាពម្ចាស់ការរបស់សហគមន៍ ចំណែកឧបសគ្គនានា ស្ថិតនៅជុំវិញកត្តាកំណត់នៃកង្វះអាហារូបត្ថម្ភនិងវិសមភាពយេនឌ័រ។ ផ្ដើមចេញពីមេរៀនទាំងនេះ សកម្មភាពជលផលតាមវាលស្រែនាពេលអនាគត ក្នុងគោលបំណងធ្វើសមាហរណកម្មសកម្មភាពអាហារូបត្ថម្ភ និងយេនឌ័រ គួរតែពិចារណាអំពី៖

១. ការគាំទ្រដល់ភាពម្ចាស់ការរបស់សហគមន៍៖ បង្កើតទំនាក់ទំនងជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន លើកទឹកចិត្តឱ្យមានចំណងទាក់ទងរវាងថ្នាក់ដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ព្រមទាំង បញ្ជូលសកម្មភាពអាហារូបត្ថម្ភនិងយេនឌ័រ ទៅក្នុងរចនាសម្ព័ន្ធសហគមន៍ដែលមានស្រាប់ (ផ្លូវការនិងមិនផ្លូវការ)។

២. ការប្រើប្រាស់ឧបករណ៍ច្នៃប្រឌិត៖ ដើម្បីឆ្លើយតបនឹងកម្រិតទាបនៃការចេះអក្សរ សូមប្រើឧបករណ៍នានាដែលសង្កត់ធ្ងន់លើការបញ្ជូនសារចក្ខុទស្សន៍និងសោតទស្សន៍ ក៏ដូចជា ការបណ្ដុះបណ្ដាល តាមរយៈអន្តរកម្ម ការហ្វឹកហាត់ និងការរៀនផងធ្វើផង។ ក្នុងករណីដែលការអនុវត្តបង្ហាញពីការចំអិនអាហារផ្ទាល់ ទាមទារពេលវែងពេក ឬមិនអាចធ្វើបាន ការប្រើប្រាស់វីដេអូសម្រាប់ការបង្ហាញអំពីការចំអិនអាហារ អាចជាជម្រើសដ៏មានប្រយោជន៍។

៣. ដោះស្រាយបញ្ហាជាឫសគល់៖ គាំទ្រដល់ការកែប្រែដើម្បីឱ្យមាននិយាមសមធម៌យេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី ក៏ដូចជា ការអប់រំស្ត្រីដើម្បីបង្កើនទំនុកចិត្ត និងសមត្ថភាពផ្ទាល់ខ្លួន ដើម្បីចូលរួមក្នុងការសម្រេចចិត្តនិងក្នុងតួនាទីជាអ្នកដឹកនាំ។

៤. ការអនុវត្តសកម្មភាពតាមបរិបទជាក់លាក់៖ ស្វែងយល់ពីឧបសគ្គចំពោះការកែប្រែឥរិយាបថជាវិជ្ជមានលើផ្នែកអាហារូបត្ថម្ភ និង WASH និងការចូលរួមរបស់ស្ត្រីក្នុងគណៈកម្មការ CFR ដោយកែសម្រួលគោលការណ៍ណែនាំដើម្បីបំពេញតាមតម្រូវការជាក់លាក់របស់សហគមន៍នីមួយៗ។



*រូបថតទី ៩៖ អ្នកអនុវត្តពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បណ្ដុះបណ្ដាលអំពីអត្ថប្រយោជន៍នៃការបរិភោគត្រីល្អិតៗក្នុងមូលដ្ឋាន*

# ឯកសារយោង


Development Initiatives Poverty Research. (2020). *2020 Global Nutrition Report: Action on equity to end malnutrition*. *The Global Nutrition Report's Independent Expert Group*.

FAO, IFAD, UNICEF, WFP, & WHO. (2021). *The State of Food Security and Nutrition in the World 2021: Transforming Food Systems for Food Security, Improved Nutrition and Affordable Healthy Diets for All*. *the State of the World*. Rome, FAO. Retrieved from https://doi.org/10.4060/ca9692en

Freed S, Kura Y, Sean V, Mith S, Cohen P, Kim M, Thay S, Chhy S (2020) Rice field fisheries: Wild aquatic species diversity, food provision services and contribution to inland fisheries. *Fisheries Research* 229:105615. doi.org/10.1016/j.fishres.2020.105615 [Video summary: https://www.youtube.com/watch?v=qc1K-MUCQOQ ]

Guttman, H., & Gregory, R. (2002). *The Ricefield Catch and Rural Food Security*.
Joffre O, Mam K, Kura Y, Pich S, and Nao T (2012) Community Fish Refuges in Cambodia – Lessons Learned. The WorldFish Center, Phnom Penh, Cambodia.

Karpati, J., Neubourg, C. de, Laillou, A., & Poirot, E. (2020). Improving children's nutritional status in Cambodia: Multidimensional poverty and early integrated interventions. *Maternal & Child Nutrition*, *16*(S2), e12731. https://doi.org/10.1111/MCN.12731

Kumar, N., Nguyen, P. H., Harris, J., Harvey, D., Rawat, R., & Ruel, M. T. (2018). What it takes: evidence from a nutrition- and gender-sensitive agriculture intervention in rural Zambia. *Journal of Development Effectiveness*, *10*(3), 341–372. https://doi.org/10.1080/19439342.2018.1478874

National Institute of Statistics, Directorate General for Health, & ICF International. (2015). *Cambodia Demographic and Health Survey 2014*. Phnom Penh, Cambodia.

Ruel, M. T., & Alderman, H. (2013). Nutrition-sensitive interventions and programmes: how can they help to accelerate progress in improving maternal and child nutrition? *The Lancet*, *382*(9891), 536–551. https://doi.org/https://doi.org/10.1016/S0140-6736(13)60843-0

Shams, N., Tuy, S., & Gutierrez., D. (2001). *Much more than rice: Rice field biodiversity and food security in Southeastern Cambodia.*

Sieu, S., Kim, M., Sean, V., & Try, V. (2015). *Rice Field Fisheries Enhancement Project (RFFEP) Biological Monitoring: Trends Over 3 Years.* Phnom Penh, Cambodia.

The WorldFish Center. (2010). Gender and fisheries: Do women support, complement or subsidize men's small-scale fishing activities? Key Messages. *Issues Brief 2108*, (November 2014), 8.
Viseth, H., Leap, H., Savry, C., H., T., & Doi., M. (2008). *Propagation of rice-field fish resources for rural communities through establishment of dry season fish refuges in Cambodia.*

# ឧបសម្ព័ន្ធ ១៖ សញ្ញាណ និងសារសំខាន់ៗអំពីអាហារូបត្ថម្ភ និង WASH សម្រាប់បណ្ណុះ បណ្តាលអ្នកថែទាំកុមារ

| ល.រ | ប្រធានបទ & សារដែលពាក់ព័ន្ធ | មធ្យោបាយទំនាក់ទំនង | | |
|---|---|---|---|---|
| | | ផ្ទាំងរូបភាព | វីដេអូនិងសម្លេង | ល្បែង/សកម្មភាព |
| 1 | *របបអាហារសមស្របសម្រាប់ស្ត្រីមានផ្ទៃពោះនិងបំបៅដោះកូន និងកុមារចាប់ពីអាយុ ៦-២៤ ខែ* | | | |
| 1.1 | អាហារ ៣ ក្រុមសម្រាប់ផ្តល់ថាមពល ការលូតលាស់ និងការពារ | ផ្ទាំងរូបភាពអាហារបីក្រុម | ខ្សែអាត់សម្លេងពី NOURISH អំពីអាហារមានប្រភពពីសាច់សត្វ វីដេអូពី WorldFish អំពីត្រីល្អិត | |
| 1.2 | ត្រីល្អិតក្នុងអាហារូបត្ថម្ភ | ផ្ទាំងរូបភាពត្រីល្អិតៗនិងសមាសធាតុមីក្រូសារធាតុចិញ្ចឹមក្នុងត្រីល្អិត | | |
| 1.3 | តម្រូវការអាហារូបត្ថម្ភផ្សេងៗគ្នានៃកុមារនៅពេលពួកគេធំឡើង | ផ្ទាំងរូបភាពអំពីកុមារក្នុងវ័យផ្សេងៗគ្នា | | |
| **2** | *របៀបបញ្ចូលត្រីទៅក្នុងរបបអាហារប្រចាំគ្រួសារ* | | | |
| 2.1 | បរិមាណអាហារសម្រាប់កុមារក្នុងវ័យខុសៗគ្នា | ផ្ទាំងរូបភាពអំពីបរិមាណអាហារត្រូវផ្តល់នៅវ័យខុសៗគ្នា | ខ្សែអាត់សម្លេងពី NOURISH អំពីបរិមាណអាហារ | ការអនុវត្តបង្ហាញជាក់ស្តែង |
| 2.2 | កម្រិតញឹកញាប់នៃការផ្តល់អាហារដល់កុមារតាមវ័យផ្សេងៗគ្នា | ផ្ទាំងរូបភាពពីកម្រិតញឹកញាប់នៃការផ្តល់អាហារដល់កុមារនៅវ័យខុសៗគ្នា | អាត់សម្លេងពី NOURISH អំពីភាពស៊ីសង្វាក់គ្នានៃអាហារ | ការអនុវត្តបង្ហាញជាក់ស្តែង |
| 2.3 | ការផ្តល់អាហារបន្ថែម | ផ្ទាំងរូបភាពនៃការផ្តល់អាហារ | | |
| 2.4 | វិធីបញ្ចូលអាហារពីឆ្នាំងគ្រួសារទៅក្នុងអាហាររបស់កុមារ | ផ្ទាំងរូបភាពពីរបៀបយកអាហារពីឆ្នាំងគ្រួសារនិងកិនបំបែកឱ្យសមស្របជាអាហារសម្រាប់កុមារ | | |
| 2.5 | ការកែច្នៃនិងរក្សាទុកត្រីល្អិតៗ សម្រាប់រដូវប្រាំង | ផ្ទាំងរូបភាពម្សៅត្រី | អាត់សម្លេងនិងវីដេអូពី NOURISH អំពីម្សៅត្រី | ការអនុវត្តបង្ហាញពីការចម្អិនអាហារ |

| | | | | |
|---|---|---|---|---|
| 2.6 | វិធីបញ្ចូលត្រីល្អិតៗទាំងមូលទៅក្នុងរបបអាហាររបស់កុមារ៖ ស៊ុបត្រី | ផ្ទាំងរូបភាពអំពីស៊ុបត្រី | | ការអនុវត្តបង្ហាញពីការចម្អិនអាហារ |
| 2.7 | វិធីដើម្បីបញ្ចូលត្រីល្អិតៗទាំងមូលក្នុងរបបអាហារកុមារ៖ ត្រីកិន | ផ្ទាំងរូបភាពត្រីកិន | | ការអនុវត្តបង្ហាញពីការចម្អិនអាហារ |
| 2.8 | របៀបធ្វើនិងផ្តល់អាហារសម្រន់សមស្របដល់កុមារ | ផ្ទាំងរូបភាពអាហារសម្រន់ដែលជួយឱ្យសុខភាពល្អ | | |
| **3** | ***អត្ថប្រយោជន៍នៃច្បារដំណាំ និងរបៀបបង្កើតនិងគ្រប់គ្រងច្បារដំណាំតាមគ្រួសារ*** | | | |
| 3.1 | ច្បារដំណាំប្រចាំគ្រួសារ | | វីដេអូពីមជ្ឈមណ្ឌលបន្លែពិភពលោក អាត់សម្លេងពី NOURISH អំពីច្បារដំណាំតាមគ្រួសារ | ការអនុវត្តបង្ហាញជាក់ស្តែង |
| 3.2 | ការដាំបន្លែតាមផើងតូចៗ | | | |
| 3.3 | ជីកំប៉ុស្តិ៍រឹង | | | |
| 3.4 | ជីកំប៉ុស្តិ៍រាវ | | | |
| **4** | ***ការអនុវត្តល្អលើផ្នែកទឹកស្អាត អនាម័យ និងការរស់នៅស្អាត*** **(WASH)** | | | |
| 4.1 | បរិស្ថានផ្ទះសំបែងស្អាត | ផ្ទាំងរូបភាពអំពីផ្ទះដែលមាន និងគ្មានអនាម័យល្អ | វីដេអូអំពីផ្ទះស្អាត& ដែលមានអនាម័យល្អ | ការបញ្ចាំងវីដេអូ |
| 4.2 | ការលាងដៃជាមួយសាប៊ូនិងទឹក | រួមបញ្ចូលក្នុងផ្ទាំងរូបភាពអំពីអនាម័យជាមូលដ្ឋានបរិមាណអាហារ | ការលាងដៃ, វីដេអូ និងអាត់សំលេងពី UNICEF, BBC & NOURISH | ការអនុវត្តបង្ហាញជាក់ស្តែងអំពីការតម្លើង |
| 4.3 | ផឹកទឹកស្អាត | រួមបញ្ចូលនៅក្នុងផ្ទាំងរូបភាពស្តីពីអនាម័យជាមូលដ្ឋាន ប្រភពនៃជំងឺរាក | វីដេអូ និងអាត់សម្លេងពី 1001 Fontaines, Malteser & NOURISH | |
| 4.4 | ការរៀបចំនិងការទុកដាក់ម្ហូបអាហារប្រកបដោយអនាម័យ | រួមបញ្ចូលនៅក្នុងផ្ទាំងរូបភាពស្តីពីបរិមាណអាហារ ប្រភពនៃជំងឺរាក គន្លឹះ ៥ នៃសុវត្ថិភាពម្ហូបអាហារ | | |
| 4.5 | ការបន្ទោរបង់ | រួមបញ្ចូលនៅក្នុងផ្ទាំងរូបភាពស្តីពីប្រភពជំងឺរាក | បង្គន់ ចំណុចសំខាន់ៗ ចំនួន ១៧, វីដេអូ និងអាត់សម្លេងពីUNICEF & NOURISH | |

## ឧបសម្ព័ន្ធ ២៖ ការណែនាំសម្រាប់សម្របសម្រួលទក្ខបង្កើតចក្ខុវិស័យតាមគ្រួសារ

| ជំហាន | ដំណើរការ |
|---|---|
| ជំហានទី១៖ សេចក្តីផ្តើម | ១. ការណែនាំខ្លួនដោយខ្លួនឯង៖ ឈ្មោះ មុខងារ និងស្ថានភាព/តួនាទីក្នុងគ្រួសារ<br>២. អ្នកសម្របសម្រួលប្រាប់កសិករអំពី គោលបំណង និងក្រមសីលធម៌ក្នុងការថតរូប និងព័ត៌មានដែលត្រូវប្រើ<br>៣. ធ្វើបញ្ជីឈ្មោះអ្នកចូលរួមក្នុងគ្រួសារ (ឈ្មោះ ភេទ កម្រិតសិក្សា តួនាទីក្នុងគ្រួសារ)<br>៤. ភ្ជាប់សំណួរនានាទៅជំហានបន្ទាប់៖<br>ក សួរសមាជិកគ្រួសារអំពីការយល់ឃើញ និងការអនុវត្តនាពេលបច្ចុប្បន្នដែលបង្កជាសម្ពាធបន្ថែមលើបុរសនិងស្ត្រីក្នុងភូមិ និងក្នុងគ្រួសារ ដើម្បីទទួលយកចំណេះដឹង ជំនាញការអភិវឌ្ឍ និងបច្ចេកទេសថ្មីៗ (ដូចជា ការចិញ្ចឹមត្រីល្អិតៗ ការបរិភោគត្រីល្អិតៗ អាហារូបត្ថម្ភ អនាម័យ ...)<br>ខ តើអ្នកយល់យ៉ាងណាអំពីនិយាម ទម្លាប់ពីបូរាណទាំងនោះ? ហេតុអ្វី? |
| ជំហានទី២៖ សកម្មភាពការងារប្រចាំថ្ងៃ (២៤ ម៉ោង/ថ្ងៃ) | ១. ស្នើសមាជិកគ្រួសារឱ្យកំណត់ និងសរសេរលើក្រដាសមួយសន្លឹក នូវសកម្មភាពការងារដែលបុរសនៅក្នុងគ្រួសារបានធ្វើ និងលើក្រដាសមួយសន្លឹកផ្សេងទៀត នូវសកម្មភាពទាំងអស់ដែលស្ត្រីធ្វើ។ អ្នកសម្របសម្រួលកត់ត្រានូវការងាររបស់បុរសនិងស្ត្រីដែលមានលើផ្ទាំងក្រដាស និងសុំឱ្យពួកគាត់បន្តសកម្មភាពរបស់ខ្លួនសម្រាប់ពេល ២៤ ម៉ោង។<br>២. ណែនាំពួកគេនូវសញ្ញាណនៃតួនាទីក្នុងការផលិត និងក្នុងការបន្តពូជ សួរគាត់ថា តើសមាជិកគ្រួសារ(ប្រុសនិងស្រី)យល់យ៉ាងណា ពីរបៀបដែលពួកគាត់បែងចែកប្រភេទការងារ? ហេតុអ្វី? បន្ទាប់មក នាំពួកគាត់មកសង្កេតសកម្មភាពនីមួយៗដែលពួកគេបានចុះក្នុងបញ្ជីសម្រាប់បុរសនិងស្ត្រីថា តើនោះជាសកម្មភាព"បន្តពូជ"សកម្មភាព "ផលិត" ឬសកម្មភាព"សហគមន៍" ដោយប្រើតារាងខាងក្រោម។ |
| ជំហានទី៣៖ ការបង្កើតចក្ខុវិស័យតាមគ្រួសារ និងការរៀបចំផែនការ | ១. **ការបង្កើតក្តីស្រមៃ៖** ដំណើរការបង្កើតចក្ខុវិស័យ ផ្អែកលើការរៀបចំផែនការតាមក្តីស្រមៃរបស់គ្រួសារ។ ការចំណាយពេលគិតអំពីអ្វីដែលសំខាន់សម្រាប់គ្រួសារអ្នក និងជីវិតរបស់អ្នក គឺជាចំណុចសំខាន់។ សរសេរក្តីស្រមៃដែលពាក់ព័ន្ធនឹងគោលដៅនៃគម្រោង។<br>២. **ស្វ័យវាយតម្លៃ៖** ស្នើឱ្យស្វាមីនិងភរិយាធ្វើការវាយតម្លៃខ្លួនឯង តាមមាត្រដ្ឋានពី១ ដល់៥៖ កម្រិត១៖ ដឹងដែរ តែមិនដែលធ្វើ; កម្រិត២៖ បានដឹង/ឮ និងបានគ្រោងធ្វើ (ប៉ុន្តែមិនទាន់ចាប់ផ្តើម); កម្រិត៣៖ បានធ្វើនៅពេលខ្លះ; កម្រិត៤៖ បានធ្វើញឹកញាប់; កម្រិត៥៖ ការធ្វើនោះបានក្លាយជាទម្លាប់។ សួរសមាជិកគ្រួសារ (ប្តី ប្រពន្ធ និងកូន)ថា៖ តើឥឡូវ ក្តីស្រមៃទាំងនេះស្ថិតនៅឯណា ឬតើក្តីស្រមៃនេះ បច្ចុប្បន្នមានសភាពបែបណា និងហេតុអ្វី? តើធ្វើដូចម្តេចដើម្បីឱ្យវាកើតមានឡើងក្នុងរយៈពេលបីឆ្នាំខាងមុខ? តើអ្នកទាំងអស់គ្នាជួយគ្នាយ៉ាងដូចម្តេច ដើម្បីឱ្យក្តីស្រមៃនេះក្លាយជាការពិត?<br>៣. ក្តីស្រមៃជាអាទិភាព៖ បោះឆ្នោតជ្រើសយកធាតុផ្សំជាអាទិភាពនៃក្តីស្រមៃ ដែលអាចអនុ |

| | |
|---|---|
| | វត្តបានក្នុងរយៈពេល ១ឆ្នាំ ដោយផ្អែកលើធនធាននិងសមត្ថភាពរបស់អ្នក។ ធាតុផ្សំជាអាទិភាពនៃក្តីស្រមៃ ដែលជាឧបសគ្គចំពោះបង្កើនផលិតភាពវារីវប្បកម្មនិងកសិកម្ម ទីផ្សារនិងថ្លៃ បច្ចេកវិទ្យាប្រព័ន្ធកសិកម្ម-វារីវប្បកម្ម អាហារូបត្ថម្ភនិងអនាម័យគ្រួសារ។ អ្នកចូលរួម/សមាជិកគ្រួសារ អាចពិភាក្សានិងបោះឆ្នោតជ្រើសយកធាតុផ្សំដែលជាអាទិភាពខ្ពស់បំផុតនៃក្តីស្រមៃនោះ។ អ្នកកត់ត្រា ត្រូវបម្លងយកគ្រប់ចំណុចនៃការពិភាក្សា របៀបដែលសមាជិកគ្រួសារ(ប្តី ប្រពន្ធ និងកូន)ធ្វើការសម្រេចចិត្ត អ្នកណាក្នុងចំណោមសមាជិកគ្រួសារដែលតែងតែជំទាស់។ |
| ជំហានទី ៤៖ ផែនការសកម្មភាពប្រចាំគ្រួសារ | ១. អ្នកសម្របសម្រួលរម្លឹកអ្នកចូលរួម អំពីធាតុផ្សំជាអាទិភាពនៃក្តីស្រមៃ និងពេលវេលា<br>២. អ្នកសម្របសម្រួលបំផុសគំនិតឱ្យមានការពិភាក្សាដើម្បីកែលម្អគោលបំណងសម្រាប់ធាតុផ្សំជាអាទិភាពនីមួយៗនៃក្តីស្រមៃនោះ<br>៣. អ្នកសម្របសម្រួលបង្ហាញតារាងផែនការគ្រួសារ និងខ្លឹមសារនៃជួរឈរនីមួយៗ<br>៤. អ្នកចូលរួមធ្វើការពិភាក្សានិងចាប់ផ្តើមបំពេញតារាងផែនការសកម្មភាពគ្រួសារ ដោយមានអ្នកសម្របសម្រួលជួយនៅក្នុងការបំពេញតារាងនេះ។ |

# ឧបសម្ព័ន្ធ ៣៖ ការណែនាំសម្រាប់រៀបចំពិព័រណ៌ភូមិ

| អ្នកពាក់ព័ន្ធ | តួនាទី |
|---|---|
| ១. គ្រួសារដែលបានជ្រើសយក (១ ឬ ២ ឬ ៣) | ១. បង្ហាញផែនទីចក្ខុវិស័យ (មុនអន្តរាគមន៍និងក្រោយអន្តរាគមន៍) បន្ទាប់មកពន្យល់ផែនទីទាំងពីរនេះដល់អង្គប្រជុំ។<br>២. បង្ហាញផ្ទះនៃគ្រួសារដែលជ្រើសយក ដោយបង្ហាញពីសមិទ្ធផលរបស់គាត់ ដូចជាច្បារដំណាំ ធុងសំរាម បរិស្ថានស្អាតនៅជុំវិញផ្ទះ កន្លែងលាងដៃ ដល់ភ្ញៀវ/អ្នកភូមិដទៃទៀត ដែលចូលរួមក្នុងពិព័រណ៌ភូមិ។ ភ្ញៀវអាចមើលឃើញផ្ទាល់ពីការផ្លាស់ប្តូរវិជ្ជមាន<br>៣. ប្រាប់បញ្ហាប្រឈមដែលពួកគាត់ជួបប្រទះ និងរបៀបដោះស្រាយបញ្ហាទាំងនោះ<br>៤. ប្រាប់អំពីអត្ថប្រយោជន៍នៃការកែប្រែក្នុងគ្រួសារ។ |
| **២. អ្នកសម្របសម្រួល** | **<u>តួនាទីទូទៅ</u>**<br>១. អញ្ជើញមនុស្សមួយចំនួន (២០-៤០ នាក់) ឱ្យចូលរួមក្នុងព្រឹត្តិការណ៍នេះ។<br>២. ធានាថាគ្រួសារដែលបានជ្រើសរើស បានដាក់តាំងសម្ភារះរបស់ពួកគេយ៉ាងមានរបៀប និងចាត់ចែងកន្លែងសមស្របសម្រាប់ភ្ញៀវអង្គុយ។<br>៣. ស្វាគមន៍អ្នកចូលរួម និងពន្យល់ពួកគាត់អំពីគោលបំណងនៃព្រឹត្តិការណ៍ក្នុងថ្ងៃនេះ។<br>៤. អញ្ជើញអាជ្ញាធរមូលដ្ឋាន និងមណ្ឌលសុខភាពឃុំ/ក្រុមទ្រទ្រង់សុខភាពភូមិ ដើម្បីថ្លែងសុន្ទរកថាខ្លីៗ។<br>៥. អញ្ជើញគ្រួសារគំរូឱ្យបង្ហាញពីសំភារៈនិងលទ្ធផលដែលបានបញ្ជាក់ខាងលើ។<br>៦. សម្រួលឱ្យមានសំណួរនិងចម្លើយរវាងគ្រួសារដែលបានជ្រើសយកនិងអ្នកចូលរួម។<br>៧. ការឆ្លុះបញ្ចាំងនិងការប្តេជ្ញាចិត្តពីអ្នកចូលរួម។<br>**<u>តួនាទីជាក់ស្តែងនៅក្នុងវគ្គនេះ</u>**<br>**ផ្នែកទី ១៖**<br>ពន្យល់ពីគោលបំណងនៃពិព័រណ៌គ្រួសារនេះដល់អ្នកចូលរួម<br>**ផ្នែកទី ២៖**<br>១. អ្នកសម្របសម្រួលស្នើឱ្យគ្រួសារគំរូធ្វើការបង្ហាញផែនទីចក្ខុវិស័យដែលពួកគាត់បានបង្កើតឡើងនៅមុនពេលអនុវត្តគម្រោង ដែលរួមទាំងរូបថតគ្រួសារនេះផងដែរ។<br>២. អ្នកសម្របសម្រួលស្នើគ្រួសារគំរូ បង្ហាញពីផែនទីចក្ខុវិស័យ ដែលពួកគាត់បានធ្វើបច្ចុប្បន្នភាព បន្ទាប់ពីបានអនុវត្តគម្រោង ដែលរួមទាំង រូបថតគ្រួសារនេះផងដែរ ឧទាហរណ៍ រូបថតប្តីជួយធ្វើម្ហូប បញ្ចុកចំណីកូន សម្អាតផ្ទះសំបែង ថែច្បារដំណាំ និងពន្យល់រូបថតទាំងនេះដល់អ្នកចូលរួមទាំងអស់។<br>៣. អ្នកសម្របសម្រួលស្នើឱ្យគ្រួសារគំរូនេះ ប្រាប់រឿងពិតអំពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ និងវិធីដោះស្រាយបញ្ហារបស់ពួកគាត់។<br>៤. អ្នកសម្របសម្រួលស្នើគ្រួសារគំរូនេះ ចែករំលែកការយល់ឃើញរបស់ខ្លួន អំពីអត្ថប្រយោជន៍នៃវិធីសាស្ត្រនេះ (ចក្ខុវិស័យតាមគ្រួសារ)។ ចូរប្រើរូបថតសម្រាប់ការឆ្លើយ |

| | |
|---|---|
| | តបទៅនឹងសំណួរ។<br>៥. អ្នកសម្របសម្រួលស្នើឱ្យគ្រួសារគំរូពិនិត្យមើលផែនការសកម្មភាពបន្ទាប់របស់ពួកគាត់ និងផ្តល់យោបល់តប អំពីនិរន្តរភាពនៃវិធីសាស្រ្តនេះ។<br>៦. អនុញ្ញាតឱ្យអ្នកចូលរួមលើកសំណួរទៅគ្រួសារគំរូ ដើម្បីសុំការបំភ្លឺ និងស្វែងយល់ឱ្យកាន់តែច្បាស់។<br>**ផ្នែកទី ៣៖**<br>ចូរសម្របសម្រួលតួនាទីបីយ៉ាង ដែលជាឧបករណ៍ជម្រុញឱ្យមានការលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ឱ្យចូលរួមយ៉ាងសកម្មក្នុងការអនុវត្តរបៀបរស់នៅស្អាត អាហារូបត្ថម្ភ និងអនាម័យនៅតាមផ្ទះ។ ចំណុចទាំងនេះ មានដូចខាងក្រោម៖<br>១. សម្រួលឱ្យមានការប្តូរវេនគ្នា ដើម្បីពន្យល់ពីបញ្ហាប្រឈមក្នុងការកែប្រែឥរិយាបថ។<br>២. បង្ហាញរូបថតដែលបញ្ជាក់ថា គ្មានអ្វីធ្វើមិនកើតឡើយ (៤ រូបថត) ហើយសុំឱ្យពួកគេនិយាយជាមួយគ្នាអំពី (របៀបរស់នៅស្អាត អនាម័យ និងអាហារូបត្ថម្ភសម្រាប់កូនៗរបស់យើង គឺសុទ្ធតែអាចធ្វើបាន)<br>៣. សម្រួលការបង្ហាញផែនទីចក្ខុវិស័យតាមគ្រួសារ ជាមួយរូបថត (បរិស្ថានផ្ទះសំបែងមិនស្អាត បរិស្ថានផ្ទះសំបែងស្អាត និងរូបថតសមាជិកគ្រួសារ ដែលមានចាប់ពីកូន ដល់ជីដូនជីតា។<br>៤. សុំការប្តេជ្ញាចិត្តរបស់ពួកគាត់ និងគ្រោងទៅលេងគ្រួសាររបស់ពួកគាត់។ |
| ៣. អ្នកចូលរួម (ភរិយា និងស្វាមី) | ១. សិក្សាពីគ្រួសារដែលបានជ្រើសយក ចែករំលែកបទពិសោធន៍និងបញ្ហាប្រឈមដែលពួកគាត់បានជួបប្រទះ ក្នុងការអនុវត្តផែនការសកម្មភាពរបស់ពួកគាត់ ដូចមានបង្ហាញក្នុងផែនទីចក្ខុវិស័យសម្រាប់គ្រួសារគាត់។<br>២. រកមើលអនុសាសន៍ និងចម្លើយពីមណ្ឌលសុខភាព/ក្រុមទ្រទ្រង់សុខភាពភូមិ/អ្នកសម្របសម្រួល/អ្នកដទៃទៀតដែលបានជ្រើសឱ្យចូលរួម<br>៣. ចែករំលែកការប្តេជ្ញាចិត្ត យ៉ាងហោចសកម្មភាពមួយ នៅពេលត្រឡប់មកផ្ទះវិញ។ |
| ៤. ក្រុមទ្រទ្រង់សុភាពភូមិ | ១. ដើរតួជាគ្រួសារគំរូនៅក្នុងភូមិ។ ធានាថា ពួកគាត់អាចជាគ្រួសារគំរូ លើការរស់នៅស្អាត និងអនាម័យ។<br>២. កត់ត្រាការប្តេជ្ញាចិត្តរបស់អ្នកចូលរួមនិងជួយពួកគាត់ឱ្យសម្រេចសកម្មភាពទាំងនោះ។<br>៣. គាំទ្រគ្រួសារនិងអ្នកចូលរួមមួយចំនួន លើបច្ចេកទេសអនាម័យនិងនៃការរស់នៅស្អាត។ |
| បុគ្គលិកមណ្ឌលសុខភាពឃុំ | ១. ទទួលស្គាល់និងគាំទ្រក្រុមទ្រទ្រង់សុខភាពភូមិ ដោយអញ្ជើញពួកគាត់ចូលរួមក្នុងកិច្ចប្រជុំការបណ្តុះបណ្តាល សិក្ខាសាលានិងធានាថា ពួកគាត់បំពេញតួនាទីរបស់ខ្លួនតាមការព្រមព្រៀងគ្នា រវាងក្រុមទ្រទ្រង់សុខភាពភូមិ និងបុគ្គលិកមណ្ឌលសុខភាពឃុំ។<br>២. សុំឱ្យក្រុមទ្រទ្រង់សុខភាពភូមិ ធ្វើរបាយការណ៍ជាប្រចាំដល់ពួកគាត់ អំពីវឌ្ឍភាពនៃគ្រួសារគំរូនៅក្នុងភូមិរបស់ពួកគាត់។<br>៣. ផ្តល់អនុសាសន៍និងការគាំទ្រ ទៅតាមតួនាទីនិងការទទួលខុសត្រូវរបស់ពួកគាត់ |

| | |
|---|---|
| | ចំពោះគ្រួសារគំរូ តាមរយៈក្រុមទ្រទ្រង់សុខភាពភូមិ ឬមកជួបផ្ទាល់។ |

# ឧបសម្ព័ន្ធ ៤៖ ផ្ទាំងរូបភាពអំពីរបៀបធ្វើម្សៅត្រី

## ការធ្វើម្សៅត្រី



**ជំហាន១.** លាងត្រី ទុកត្រីឱ្យស្រស់ទឹកក្នុងកញ្ច្រែងមួយ



**ជំហាន២.** លីងត្រីដែលលាងរួចក្នុងខ្ទះមួយ



**ជំហាន៣.** លីងដោយប្រើកំដៅមធ្យម និងកូររហូតត្រីស្ងួត



**ជំហាន៤.** បុកត្រីលីងរួចដោយប្រើត្បាល់ និងអង្រែ



**ជំហាន៥.** រក្សាទុកម្សៅត្រីក្នុងកែវបិទគ្របជិតបានរហូត៤ខែ



**ជំហាន៦.** បន្ថែមម្សៅត្រីក្នុងអាហារចំអិនរួច មុនបរិភោគ

WorldFish

## អំពីអង្គការ វើលហ្វីស

វើលហ្វីស ជាអង្គការស្រាវជ្រាវអន្តរជាតិ មិនស្វែងរកផលចំណេញ ដែលប្រើប្រាស់សក្តានុពលនៃធនធានជលផល និងវារីវប្បកម្ម ដើម្បីកាត់បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រ។ នៅទូទាំងពិភពលោក ប្រជាពលរដ្ឋក្រីក្រជាងមួយពាន់លាននាក់ទទួលបានប្រូតេអ៊ីនពីសាច់សត្វ ភាគច្រើនពីត្រី ហើយពលរដ្ឋ ៨០០លាននាក់ ពឹងផ្អែកលើធនធានជលផល និងវារីវប្បកម្ម សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ WorldFish គឺជាសមាជិកនៃ CGIAR ដែលជា ដៃគូស្រាវជ្រាវសកលដើម្បីជានាសន្តិសុខស្បៀងទៅអនាគត។

ចំពោះព័ត៌មានបន្ថែម សូមអានក្នុង៖ www.worldfishcenter.org